**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៨)

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២១

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 09-Jul-2021, 10:35
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើរបស់ មាស មុត សុំបញ្ចប់ ចោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ នៅក្នុងបណ្ណសារ**

---

**ដាក់ដោយ** ÷

**សហមេធាវី** ៖

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន** ÷

**ចៅក្រមអង្គបុរេជំនុំជម្រះ** ៖

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហ្វូត វុទ្ធី

ចៅក្រម Olivier BEAUVALLET

ចៅក្រម BAIK Kang Jin

ចៅក្រមបម្រុង Steven J. BWANA

ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី

០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៨)

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តី ០០៣**

សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ

Original EN: 01673205-01673235

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") អនុលោមតាមភារកិច្ចរបស់អង្គបុរេជំនុំជម្រះ ("អ.ប.ជ.") ក្នុងការប្រកាស ក្នុងនាមជាយុត្តាធិការចុងក្រោយបង្អស់ ទៅលើដំណាក់កាលស៊ើបអង្កេត[1] ដែលជា "កិច្ចខិតខំប្រឹងប្រែងចំពោះសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព" តាមវិធាន ២១ នៃវិធានផ្ទៃក្នុង[2] ជាយុត្តាធិការជាមូលដ្ឋាន[3] និង អំណាចក្នុងការសម្រេចទៅលើបញ្ហាដែលមានសារៈសំខាន់ជាទូទៅសម្រាប់យុត្តិសាស្ត្រ និង កេរដំណែលរបស់ អ.វ.ត.ក.[4] សូមស្នើឱយអង្គជំនុំជម្រះ បញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ជាបន្ទាន់។ មេធាវីការពារក្តីស្នើសុំដាក់សំណើនេះជាភាសាអង់គ្លេសជាមុនសិន ដោយដាក់ការបកប្រែជាភាសាខ្មែរជូនតាមក្រោយ ពីព្រោះថាអង្គភាពបកប្រែភាសា មិនអាចបញ្ចប់ការបកប្រែនៅក្នុងរយៈពេលសមស្របបាន[5]។

## I. សាវតារ

១. លោក មាស មុត ស្ថិតក្រោមការស៊ើបអង្កេតអស់រយៈពេល ១៣ ឆ្នាំមកហើយ។ សហចៅក្រមស៊ើបអង្កេតជាតិមួយនាក់ និង សហចៅក្រមស៊ើបអង្កេតអន្តរជាតិប្រាំនាក់ ("ស.ច.ស.") បានស៊ើបអង្កេតលើរឿងក្តីនេះ។ នៅពេលបិទបញ្ចប់ការស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ.") យូ ប៊ុនឡេង និង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ.") ចុងក្រោយបង្អស់នៅ អ.វ.ត.ក. គឺ Michael Bohlander បានជ្រើសរើសមិនស្នើឱយ អ.ប.ជ. ពិនិត្យលើការខ្វែងយោបល់គ្នារបស់ពួកគាត់ ដោយបានចេញដីកាដំណោះស្រាយដាច់ដោយឡែក និង ផ្ទុយគ្នា នៅក្នុងពេលដំណាលគ្នានោះ បញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ និង លើកលែងចោទប្រកាន់។ អ.ប.ជ. បានប្រកាសថា ការចេញដីកាដំណោះស្រាយទាំងនោះ គឺខុសច្បាប់ ដូចដែលពួកគាត់បានអនុវត្តនៅក្នុងរឿងក្តី ០០៤/២ ដែរ។ អ.ប.ជ. មិនបានប្រើប្រាស់ឧបាស្រ័យចំពោះដីកាដំណោះស្រាយខុសច្បាប់ ដែលអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក.") បានបញ្ជាក់នោះឡើយ នៅ

[1] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និង D360/33 ("សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២") កថាខណ្ឌ ៤១, ១២២។

[2] *ដូចខាងលើ* កថាខណ្ឌ ៦៨។

[3] *ដូចខាងលើ* កថាខណ្ឌ ៥១។

[4] *ដូចខាងលើ* កថាខណ្ឌ ៣២, ៥០។

[5] *សូមមើល* សារអេឡិចត្រូនិកពីអង្គភាពបកប្រែភាសាផ្ញើជូនមេធាវីការពារក្តី "កម្មវត្ថុ៖ សំណើសុំបកប្រែ" ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០២១ ដែលបង្ហាញថា ការបកប្រែសំណើនេះមិនអាចបញ្ចប់នោះទេ រហូតដល់ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០២១។

ពេលបញ្ចប់រឿងក្តី ០០៤/២ ផ្ទុយទៅវិញ បានបង្គាប់ណែនាំឱយបញ្ចូលរឿងក្តី ០០៣ ទៅក្នុងបណ្ណសារ និង បញ្ជូនរឿងក្តីទៅជំនុំជម្រះ។ នៅពេលស្នើសុំបញ្ជូនរឿងក្តី ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ.") ស.ច.ស. បានសម្រេចថា អ.ប.ជ. នៅតែទទួលពិនិត្យ និង ទទួលខុសត្រូវចំពោះដំណើរការនីតិវិធីមុនជំនុំជម្រះ។

២. ***សហព្រះរាជអាជ្ញាមិនបានព្រមព្រៀងគ្នាទៅលើថា តើរឿងក្តី ០០៣ គួរត្រូវបានចោទប្រកាន់ទោសដែរឬទេ។*** តាំងពីការចាប់ផ្តើមដំបូងនៃការស៊ើបអង្កេត នៅថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ.") បានស្នើឱយ អ.ប.ជ. ពិនិត្យលើការខ្វែងយោបល់គ្នាមួយ ដោយថ្លែងថា គាត់មានបំណងដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱយស៊ើបសួរថ្មី ទាក់ទងនឹងអ្វីដែលនឹងក្លាយជា រឿងក្តី ០០៣ និង ០០៤[6]។ សមភាគីជាតិរបស់គាត់ គឺសហព្រះរាជអាជ្ញាជាតិ ("ស.ព.ជ.") "ជំទាស់នឹងការចោទប្រកាន់ទៅលើបទឧក្រិដ្ឋកម្ម ដែលកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱយស៊ើបសួរថ្មី"[7] ដោយពិចារណាថា អង្គហេតុនៃរឿងក្តី ០០៣ ត្រូវបានគ្របដណ្តប់រួចហើយ ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱយស៊ើបសួរក្នុងរឿងក្តី ០០២ ហើយថា លោក មាស មុត និង ស៊ូ ម៉េត (ស៊ូ ម៉េត ក្រោយមកបានទទួលមរណភាព)[8] "មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុតនោះទេ ពីព្រោះពួកគាត់មានតួនាទីទាបក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" និងថា "សន្តិភាព ស្ថិរភាព និងការបង្រួបបង្រួមជាតិក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន គឺជាតឹកតាងប្រឆាំងទៅនឹងការផ្តួចផ្តើមគំនិតថ្មីក្នុងការចោទប្រកាន់"[9]។

៣. ***ចៅក្រមនៃ អ.ប.ជ. មិនបានព្រមព្រៀងគ្នាទៅលើថា តើរឿងក្តី ០០៣ គួរត្រូវបានចោទប្រកាន់ទោសដែរឬទេ។*** អ.ប.ជ. មិនអាចទទួលបានសំឡេងភាគច្រើនលើសលុបលើការខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញានោះទេ[10]។ ចៅក្រមជាតិនៃ អ.ប.ជ. យល់ស្របជាមួយ ស.ព.ជ. ថា អង្គ

---

[6] កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីហេតុការណ៍ និង មូលហេតុនៃការខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧១(២) ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ ១ កថាខណ្ឌ ២។

[7] *ដូចខាងលើ* កថាខណ្ឌ ១២០។

[8] ការលើកលែងការចោទប្រកាន់ប្រឆាំង ស៊ូ ម៉េត ចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០១៥ ឯកសារ D86/3។

[9] ឧបសម្ព័ន្ធ I៖ សំណៅសាធារណៈមានកោសលុប សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៩ ឯកសារ D1/1.3 កថាខណ្ឌ ២៩-៣២។

[10] *ដូចខាងលើ* កថាខណ្ឌ ៤៥។

ហេតុនៃរឿងក្តី ០០៣ ត្រូវបានគ្របដណ្តប់ដោយរឿងក្តី ០០២[11] និង យល់ឃើញថា ស.ព.អ. បាន បើកការស៊ើបអង្កេតជាឯកតោភាគី ដោយពុំបានជូនដំណឹងដល់ ស.ព.ជ.[12]។ ចៅក្រមអន្តរជាតិនៃ អ.ប.ជ. មិនយល់ស្របទៅនឹងការវាយតម្លៃរបស់ ស.ព.ជ. ចំពោះការអនុវត្តកិច្ចស៊ើបអង្កេតបឋម ដោយ ស.ព.អ. និង បានយល់ឃើញថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱយស៊ើបសួរក្នុងរឿងក្តី ០០៣ សំដៅទៅអង្គហេតុថ្មីៗបន្ថែមលើអង្គហេតុដែលត្រួតគ្នានៅក្នុងរឿងក្តី ០០២[13]។ ដោយសារថា អ.ប.ជ. ខកខានមិនអាចទទួលសំឡេងភាគច្រើនលើសលុប ការស៊ើបអង្កេតនៅតែបន្តដំណើរការ[14] ហើយនៅថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩ ស.ព.អ. ស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱយស៊ើបសួរក្នុងរឿងក្តី ០០៣[15]។

៤. ***ស.ច.ស. ចាប់ផ្តើមធ្វើការស៊ើបអង្កេត។*** ស.ច.ស.ជ. យូ ប៊ុនឡេង និង ស.ច.ស.អ. Marcel Lemonde ដែលជា ស.ច.ស.អ. ដំបូងគេបង្អស់ បានចាប់ផ្តើមការស៊ើបអង្កេត និង បង្កើតផែនការការងារលម្អិតមួយ[16]។ ស.ច.ស.ជ. និង ស.ច.ស.អ. Lemonde បានស៊ើបអង្កេតលើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តដោយខ្មែរក្រហម អស់រយៈពេលជាងពីរឆ្នាំ ដោយកំណត់ថា តើអ្នកដែលត្រូវបាន ស៊ើបអង្កេត គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ[17]។ មុន

---

[11] *ដូចខាងលើ* យោបល់របស់ចៅក្រម ប្រាក់ គឹម សាន, ន័យ ថុល និង ហួត វុទ្ធី កថាខណ្ឌ ២៧, ៣០។

[12] *ដូចខាងលើ* យោបល់របស់ចៅក្រម ប្រាក់ គឹម សាន, ន័យ ថុល និង ហួត វុទ្ធី កថាខណ្ឌ ១៨។

[13] *ដូចខាងលើ* យោបល់របស់ចៅក្រម Downing និង Lahuis កថាខណ្ឌ ៤, ២២។

[14] *សូមមើល* មាត្រា ៧(៤) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ២០០៣) ("កិច្ចព្រមព្រៀង")។ *សូមមើលផងដែរ* វិធាន ៧២(៤) នៃវិធានផ្ទៃក្នុង។

[15] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។

[16] របាយការណ៍តុលាការរបស់ អ.វ.ត.ក.៖ លេខ ២៦ (ខែមិថុនា ឆ្នាំ ២០១០) ទំព័រ ២ គេហទំព័រ https://www.eccc.gov.kh/sites/default/files/publications/The%20Court%20Report%20%5BJune%202010%5D%20FINAL.pdf។

[17] ស.ច.ស. បានប្តឹងស៊ើបអង្កេតទៅលើរឿង ០០១ និង ០០២ នៅថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៧។ *សូមមើល រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក-កសចស ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំងហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D99 កថាខណ្ឌ ៤។ *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D427 កថាខណ្ឌ ៣។

ពេល ស.ច.ស.អ. Lemonde លាលែងពីតំណែង “ទៅរៀបចំផែនការរយៈពេលវែងផ្សេងទៀត”[18] ស.ច.ស. បានប្រមូលភស្តុតាងជាង ១.១៣០ សំណៅនៅក្នុងរឿងក្តី ០០៣[19]។

៥. ***ការស៊ើបអង្កេតបញ្ចប់។*** នៅពេល ស.ច.ស.អ. Siegfried Blunk ចូលកាន់តំណែងបន្ទាប់ពី ស.ច.ស.អ. Lemonde នៅថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១០[20] គាត់បានបន្តធ្វើការស៊ើបអង្កេតជាមួយ ស.ច.ស.ជ.[21] ដោយផ្តោតទៅលើការកំណត់ថា តើ លោក មាស មុត ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ដែរឬទេ[22]។ ស.ច.ស. “បានបង្កើតក្រុមការងាររួមគ្នា”[23] “បានព្រមព្រៀងគ្នាលើវិធីស៊ើបអង្កេត”[24] និង បានស៊ើបអង្កេត “ដោយរលូន និង ដោយការព្រមព្រៀងគ្នាទាំងស្រុង”[25]។

---

[18] របាយការណ៍តុលាការរបស់ អ.វ.ត.ក.៖ លេខ ២៩ (ខែកញ្ញា ឆ្នាំ ២០១០) ទំព័រ ២ គេហទំព័រ https:// www.eccc.gov.kh/sites/default/files/publications/Court_Report_September2010.pdf។ *សូមមើលផងដែរ* គេហទំព័ររបស់ អ.វ.ត.ក. *ចៅក្រម Marcel Lemonde* គេហទំព័រ ។

[19] តាមការស្រាវជ្រាវនៅលើប្រព័ន្ធ ZyLAB បង្ហាញថា ចន្លោះពីថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១០ ការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស.”) បានដាក់ឯកសារចំនួន ១.១៣៤ ជាភាសាអង់គ្លេស ភាសាខ្មែរ និងភាសាបារាំង ទៅក្នុងសំណុំរឿង។ *សូមមើលផងដែរ* ប្រព័ន្ធ ZyLAB “សំណុំរឿង៖ CF00៣” “កាលបរិច្ឆេទដាក់ឯកសារ៖ ចន្លោះពីថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១០” និង “ភាគីដាក់ឯកសារ៖ ក.ស.ច.ស.”។ ឯកសារមួយចំនួនដែលបានដាក់ក្នុងសំណុំរឿងក្នុងអំឡុងពេលនេះ អាចជាន់គ្នា។

[20] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *បណ្ឌិត Siegfried Blunk ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី* ចុះថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១០ គេហទំព័រ ។

[21] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី* ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១១ គេហទំព័រ https://www.eccc.gov.kh/sites/default/files/documents/courtdoc/2012-12-24%2016% ។

[22] របាយការណ៍តុលាការរបស់ អ.វ.ត.ក.៖ លេខ ៣៣ (ខែកុម្ភៈ ឆ្នាំ ២០១១) ទំព័រ ៧ គេហទំព័រ https:// www.eccc.gov.kh/sites/default/files/publications/Court_Report_February_2011.pdf។

[23] របាយការណ៍តុលាការរបស់ អ.វ.ត.ក៖ លេខ ៣៣ (ខែកុម្ភៈ ឆ្នាំ ២០១១) ទំព័រ ៧ គេហទំព័រ https:// www.eccc.gov.kh/sites/default/files/publications/Court_Report_February_2011.pdf។

[24] ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ឯកសារ D266 (“ដីកាសម្រេចលើកលែងចោទប្រកាន់”) កថាខណ្ឌ ៤៨។

[25] *ដូចខាងលើ* កថាខណ្ឌ ៤១។

បន្ទាប់ពីដំណើរការបានរយៈពេលប្រាំខែរួចមក ស.ច.ស. បានប្រមូលភស្តុតាងបន្ថែម[26] និង បាន ពិនិត្យមើលភស្តុតាងដាក់បន្ទុក និង ដោះបន្ទុកជាង ៣.០០០ សំណៅ ពីរឿងក្តី ០០១ រឿងក្តី ០០២ និង រឿងក្តី ០០៣[27]។ ស.ច.ស. "ផ្តោតការយកចិត្តទុកដាក់មួយរយៈកាលទៅលើការវិភាគ ភស្តុតាងចំនួន ១០.០០០ ឯកសារ និង កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ៧០០ ដែលត្រូវបាន ប្រមូលចងក្រងនៅក្នុងរឿងក្តី ០០២ ដើម្បីស្វែងរកការពាក់ព័ន្ធនឹងរឿងក្តី ០០៣ និងរឿងក្តី ០០៤" មុនពេលបន្តការស៊ើបសួរដល់ទីកន្លែង និង ស្តាប់ចម្លើយ "សាក្សីសំខាន់ៗ" រួមទាំង ឌុច ផងដែរ[28]។ បន្ទាប់ពីការស៊ើបអង្កេតបានរយៈពេលចំនួន ២០ ខែ នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ស.ច.ស. បានបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួន ដោយ "[ការ]ព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទ" ថា មិនចោទប្រកាន់ លោក មាស មុត នោះទេ[29]។ បន្ទាប់ពីសេចក្តីថ្លែងការណ៍នៅក្នុងសារព័ត៌មាន បានចោទសួរទៅលើ បញ្ហាឯករាជ្យភាព និង សុចរិតភាពរបស់គាត់ ស.ច.ស.អ. Blunk ក៏បានលាលែងពីតំណែង[30]។

៦. ***ការស៊ើបអង្កេតបើកឡើងវិញ។*** បន្ទាប់មក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ("ស.ច.ស. អ.ប.") Laurent Kasper-Ansermet ដែលមិនធ្លាប់បានស្បថចូលកាន់តំណែងជា ស.ច.ស.អ.

---

[26] តាមការស្រាវជ្រាវនៅលើប្រព័ន្ធ ZyLAB បង្ហាញថា ចន្លោះពីថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១០ ដល់ថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ក.ស.ច.ស. បានដាក់ឯកសារចំនួន ៣០២ ជាភាសាអង់គ្លេស ភាសាខ្មែរ និងភាសាបារាំង ទៅក្នុងសំណុំរឿង ០០៣។ *សូមមើល ផងដែរ* ប្រព័ន្ធ ZyLAB "សំណុំរឿង៖ CF00៣" "កាលបរិច្ឆេទដាក់ឯកសារ៖ ចន្លោះពីថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១០ ដល់ថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១" និង "ភាគីដាក់ឯកសារ៖ ក.ស.ច.ស."។ ឯកសារមួយចំនួន ដែលបានដាក់ក្នុងសំណុំរឿងក្នុងអំឡុងពេល នេះ អាចជាន់គ្នា។

[27] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២, ៤៨, ៣៥៩។

[28] Thomas Miller *ការពិភាក្សារវាងចៅក្រមនៅសាលាក្តីខ្មែរក្រហមមានភាពចម្រូងចម្រាស់* សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះផ្សាយ នៅថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១១ *អាចមានតាមគេហទំព័រ*

។

[29] សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ ឯកសារ D13។ ដីកាសម្រេចលើកលែងចោទ ប្រកាន់ កថាខណ្ឌ ៥៣។

[30] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ គេហទំព័រ

។ ស.ច.ស.អ. Blunk បានលាលែងពីតំណែង ដោយមានអនុភាពចាប់ពីថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១១។ *សូមមើល* គេហទំព័ររបស់ អ.វ.ត.ក.៖ *បណ្ឌិត Siegfried Blunk* គេហទំព័រ https://www.eccc.gov

។

បានចូលមក[31]។ គាត់បានបើកការស៊ើបអង្កេតឡើងវិញដោយឯកតោភាគី[32] ដោយសារខ្លាចថា ស.ច.ស.ជ. នឹងចេញដីកាបញ្ជូនរឿងទៅពិនិត្យ ដែល ស.ច.ស.អ. Blunk បានព្រាងរួមគ្នា បើទោះជាគាត់បានទទួលស្គាល់ថា គាត់មិនបានពិនិត្យមើលសំណុំរឿង និង ទោះបីជា ស.ច.ស.ជ. បានដាស់តឿនឱយគាត់ពិនិត្យភស្តុតាង មុនពេល "មានចំណាត់ការតាមបែបប្រញាប់ប្រញាល់" ណាមួយក៏ដោយ[33]។ រយៈពេលប្រាំខែបន្ទាប់ពីការបើកការស៊ើបអង្កេតឡើងវិញ ស.ច.ស.អ.ប. Kasper-Ansermet បានលាលែងពីតំណែង[34]។

៧. ***លោក មាស មុត ត្រូវបានចោទប្រកាន់។*** ស.ច.ស.ជ. បានបដិសេធមិនព្រមចេញដីកាបញ្ជូនរឿងទៅពិនិត្យ ដោយរង់ចាំសមភាគីអន្តរជាតិថ្មីរបស់គាត់ គឺ ស.ច.ស.អ. Mark Harmon ឱយយល់ច្បាស់ពីសំណុំរឿងជាមុនសិន[35] ពិភាក្សាអំពីស្ថានភាពនៃការស៊ើបអង្កេត និង ចុះកំណត់ហេតុការខ្វែងយោបល់គ្នាផ្ទៃក្នុង នៅថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣[36]។ បន្ទាប់ពីការខ្វែងយោបល់គ្នា ស.ច.ស.ជ. បានចេញដីកាបញ្ជូនរឿងទៅពិនិត្យ ដោយសម្រេចថា ការស៊ើបអង្កេតបានបញ្ចប់តាំងពីនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១[37]។ ទន្ទឹមនឹងនោះ ស.ច.ស.អ. Harmon បានបន្តការស៊ើប

---

[31] សេចក្តីប្រកាសព័ត៌មានរបស់ អ.ស.ប.៖ *សេចក្តីថ្លែងការណ៍ក្នុងនាមអ្នកនាំពាក្យរបស់អគ្គលេខាធិការស្តីពីប្រទេសកម្ពុជា* ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១២ គេហទំព័រ ។

[32] ដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ ចុះថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១១ ឯកសារ D28។

[33] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ* ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១២ គេហទំព័រ ។

[34] ស.ច.ស.អ.ប. បានលាលែងពីតំណែង ដោយមានអនុភាពចាប់ពីថ្ងៃទី ៤ ខែឧសភា ឆ្នាំ ២០១២។ *សូមមើល* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង* ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១២ គេហទំព័រ ។

[35] ស.ច.ស.អ. Mark Harmon បានស្បថចូលកាន់តំណែងជា ស.ច.ស.អ. ទីបួន នៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០១២។ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *លោក Mark Harmon ស្បថចូលកាន់តំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០១២ គេហទំព័រ ។

[36] *សូមមើល* សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដាក់ប្រតិចារឹកសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ១០។

[37] ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D52។ ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣២។ *សូមមើលផងដែរ* សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីថ្លែង*

អង្កេត[38] ដោយសារតែ តាមគាត់យល់របស់គាត់ គឺ ស.ច.ស. មាន "ឆន្ទានុសិទ្ធិសម្រេចដោយឯករាជ្យ នៅពេលណាខ្លួនយល់ឃើញថា ការស៊ើបអង្កេតត្រូវបានបញ្ចប់"[39]។ ក្រោយមក នៅពេលដែល ស.ច.ស.ជ. បានផ្ញើអនុស្សរណៈមួយជូនដល់ ស.ច.ស.អ. Harmon "ទាក់ទងនឹងការបិទការស៊ើបអង្កេត និង លទ្ធភាពរបស់ [ស.ច.ស.អ.] ក្នុងការប្ដឹងឧទ្ធរណ៍ទៅកាន់ [អ.ប.ជ.] ដោយការស្នើសុំឱ្យបើកការស៊ើបអង្កេតឡើងវិញ"[40] ស.ច.ស.អ. Harmon មិនបានឆ្លើយតប និង បានបន្តការស៊ើបអង្កេត និង ប្រមូលភស្តុតាង[41]។ នៅទីបំផុត គាត់បានចោទប្រកាន់ លោក មាស មុត[42] នៅក្នុងរយៈពេលបួនខែ មុនពេលលាលែងពីមុខតំណែង "ដោយសារហេតុផលផ្ទាល់ខ្លួន"[43]។

៨. ***ស.ច.ស.អ. ចុងក្រោយបង្អស់ ស្បថចូលកាន់តំណែង។*** បន្ទាប់ពីបានស្បថចូលកាន់តំណែងនៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៥ ស.ច.ស.អ. Michael Bohlander ដែលជា ស.ច.ស.អ. ចុងក្រោយគេបង្អស់ បានសិក្សាសំណុំរឿង ធ្វើការស៊ើបអង្កេត និង ប្រមូលភស្តុតាង[44] បានចេញជាថ្មីនូវសេចក្ដីសម្រេចទាំងឡាយដែល ស.ច.ស.អ Harmon[45] បានចេញ បានលុបចោលបទចោទខ្លះ

---

*ការណ៍របស់សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងសំណុំរឿង ០០៣* ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០១៣ គេហទំព័រ ។

[38] *សូមមើល* សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដាក់ប្រតិចារិកសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ១២។ ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D54។ ដីកាចាត់ឱ្យស៊ើបសួរជំនួស ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D55។

[39] សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដាក់ប្រតិចារិកសំណុំរឿង ០០២ ចូលទៅក្នុងសំណុំរឿង ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D53/2 កថាខណ្ឌ ៥ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[40] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៤។

[41] *ដូចខាងលើ* កថាខណ្ឌ ៤៤។

[42] ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D128.1។

[43] ស.ច.ស.អ. Harmon បានលាលែងពីតំណែង ដោយមានអនុភាពចាប់ពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៥។ សេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *ចៅក្រម Harmon ប្រកាសលាលែងពីតំណែង* ចុះថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ២០១៥ គេហទំព័រ https://www.eccc.gov.kh/en/articles/judge-harmon-announces-his-resignation ។

[44] *សូមមើល ឧទា.* ការពន្យារពេលអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស D59 ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ ឯកសារ D59.13។ ការពន្យារពេលអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស D89 ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៥ ឯកសារ D89.11។

[45] សេចក្ដីជូនដំណឹងពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅភាគីនានាស្ដីពីការចេញសាឡើងវិញ នូវដីកាសម្រេចដែលចៅក្រម Harmon បានសម្រេចនៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៥ ឬ បន្ទាប់ពីកាលបរិច្ឆេទនេះ ចុះថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D149។ *សូមមើល ឧទា.* ដីកាសម្រេចចេញសាឡើងវិញលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១៥ ឯកសារ D120/3។

របស់ ស.ច.ស.អ. Harmon[46] និង បានចោទប្រកាន់លោក មាស មុត អំពីបទឧក្រិដ្ឋកម្មមួយចំនួនបន្ថែមទៀត[47]។ ស.ច.ស.ជ. បានរង់ចាំ ស.ច.ស.អ. Bohlander បញ្ចប់ការស៊ើបសួររបស់គាត់។

៩. ***វិបត្តិថវិកាគំរាមកំហែងដល់សុចរិតភាពនៃដំណើរការនីតិវិធីរបស់ អ.វ.ត.ក.*** ។ នៅពេលដែលស្ថានភាពថវិការបស់តុលាការបានឈានដល់ "ចំណុចវិបត្តិ" នៅពាក់កណ្តាលឆ្នាំ ២០១៧ ស.ច.ស. បានគ្រោងនឹងផ្អាកនីតិវិធីជាអចិន្ត្រៃយ៍[48] ដោយយល់ឃើញថា វាមិនស្របតាមតម្រូវការជាមូលដ្ឋាននៃការជំនុំជម្រះក្តីដោយយុត្តិធម៌ និង នីតិរដ្ឋ ក្នុងការចេញដីកាដំណោះស្រាយមួយ ជាពិសេសដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលអាច "តាមលងបន្លាចជនត្រូវចោទ" - ប្រសិនបើមានថវិកាមិនគ្រប់គ្រាន់សម្រាប់ឱយ អ.ប.ជ. ត្រួតពិនិត្យលើបណ្តឹងឧទ្ធរណ៍ "ហើយ តទៅមុខ នៅតែមានមន្ទិលយ៉ាងខ្លាំងអំពីការចូលរួមរបស់ភាគីទាំងឡាយ នៅក្នុងសវនាការចំពោះមុខ [អ.ជ.ស.ដ.] ... និង អ.ជ.ត.ក."[49]។ ដោយមានការផ្តល់ថវិកាជាបន្ទាន់ ស.ច.ស. បានពន្យារពេលផ្អាកនីតិវិធី ហើយរង់ចាំវឌ្ឍនភាពទៅមុខទៀត - ត្រៀមចាត់វិធានការចាំបាច់ ប្រសិនបើឯករាជ្យភាពរបស់តុលាការ ភាពយុត្តិធម៌ និង សុចរិតភាពនៃដំណើរការនីតិវិធី រងការគំរាមកំហែង[50]។

១០. ***ការស៊ើបអង្កេតបានបញ្ចប់ដោយមានតម្រុយ*** ។ បន្ទាប់ពីបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ. និង ចម្លើយរបស់មេធាវីការពារក្តី ស.ច.ស. បានជូនដំណឹងដល់ភាគីនានានៅថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ថា ស.ច.ស. បានពិចារណាទៅលើដីកាដំណោះស្រាយដាច់ដោយឡែក និង ផ្ទុយគ្នា ដោយផ្អែកលើការខ្វែងយោបល់គ្នា ដែលអាចធ្វើបាន អនុលោមតាមក្របខណ្ឌរបស់ អ.វ.ត.ក. "និង អំពីផលវិបាកដែលទំនងជាកើតមានសម្រាប់ដំណើរការបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៧

[46] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D174 ទំព័រ ១៥។

[47] *ដូចខាងលើ* ទំព័រ ១៤-១៥។

[48] សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និង ផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ D249 កថាខណ្ឌ ១, ៧៥, ៨៤។

[49] *ដូចខាងលើ* កថាខណ្ឌ ៥៣-៥៤។

[50] សេចក្តីសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និង សារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៧ ឯកសារ D249/6 កថាខណ្ឌ ៦៣, ៦៧។

(១៣) នៃវិធានផ្ទៃក្នុង"[51]។ តាមការយល់ឃើញរបស់ពួកគាត់ វិធានទាំងនេះមិនតម្រូវឱយសហព្រះរាជអាជ្ញា ឬ ស.ច.ស. ស្នើឱយ អ.ប.ជ. ពិនិត្យលើការខ្វែងយោបល់គ្នាទេ ដូច្នេះអនុញ្ញាតឱយពួកគេដាក់ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែកពីគ្នា និង ចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នាបាន[52]។ ពុំមានបណ្ដឹងឧទ្ធរណ៍ណាមួយត្រូវបានដាក់ជំទាស់នឹងសេចក្តីសម្រេចរបស់ ស.ច.ស. នោះទេ ហើយ អ.ប.ជ. ដែលត្រូវបានជូនដំណឹងជាសាធារណៈអំពីសេចក្តីសម្រេចនេះ ក៏មិនបានបង្គាប់ឱយ ស.ច.ស. ចេញដីកាដំណោះស្រាយតែមួយ ឬ ផ្តល់យោបល់ណែនាំនោះឡើយ។

១១. ***ស.ច.ស. ចេញដីកាដំណោះស្រាយរបស់ខ្លួន។*** ដូចដែលគាត់បានជូនដំណឹងដល់ភាគីនានា[53] នៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០២០ ស.ច.ស. បានចេញដីកាដំណោះស្រាយដាច់ដោយឡែក និង ផ្ទុយគ្នាដោយផ្អែកលើលទ្ធផលនៃការស៊ើបអង្កេតរបស់ពួកគាត់។ ស.ច.ស.ជ. បានសម្រេចលើកលែងចោទប្រកាន់ ដោយយល់ឃើញថា លោក មាស មុត មិនស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះទេ ពីព្រោះថា បើទោះបីជាគាត់មានតួនាទីច្រើនក៏ដោយ ក៏គាត់ "មិនមានអំណាចច្រើន" ហើយ "ការចូលរួមរបស់គាត់ មិនសកម្ម មិនជុំកំភួន និង មិនបានកៀគកិតនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ" [54]។ ស.ច.ស.អ. Bohlander បានយល់ឃើញផ្ទុយពីនេះ[55] ដោយបានចោទប្រកាន់បញ្ជូនលោក មាស មុត ទៅជំនុំជម្រះពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មជាតិ[56]។

---

[51] ដីកាដំណោះស្រាយ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ឯកសារ D267 ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") កថាខណ្ឌ ១៩។ *រឿងក្ដី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៥។

[52] *រឿងក្ដី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចលើសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D353/1 កថាខណ្ឌ ៣៥។ *រឿងក្ដី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៥។

[53] *រឿងក្ដី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៥។

[54] ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨។

[55] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦០។

[56] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទំព័រ ៤២២-៤៣១។

១២. *ភាគីទាំងឡាយប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។* នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ពួកគាត់ដែលបានដាក់នៅក្នុងថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៩ មេធាវីការពារក្តី និង ស.ព.អ. បានយល់ស្របគ្នាថា ក្របខណ្ឌ អ.វ.ត.ក. អនុញ្ញាតឱយ ស.ច.ស. ចេញដីកាដំណោះស្រាយដាច់ដោយឡែក និងផ្ទុយគ្នា ដោយសារពាក្យពេចន៍ជាឆន្ទានុសិទ្ធិនៅក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង គោលការណ៍ណែនាំលើការបកស្រាយនៅក្នុងវិធាន ១(២) នៃវិធានផ្ទៃក្នុង និង ឋានៈស្មើគ្នារបស់ ស.ច.ស. លើការស៊ើបអង្កេត ទោះបីជាមានការមិនយល់ស្របគ្នាលើបញ្ហាថា តើដីកាដំណោះស្រាយណាមួយមានឧត្តមានុភាព ក្នុងករណីដែលមិនអាចច្រានចោលដីកាដំណោះស្រាយណាមួយ ដោយសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ. ក៏ដោយ[57]។ មេធាវីការពារក្តីបានលើកទឡ្ហីករណ៍ថា ដីកាសម្រេចលើកលែងការចោទប្រកាន់ ត្រូវតែមានឧត្តមានុភាព ស្របតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* ចំណែក ស.ព.អ. បានលើកទឡ្ហីករណ៍ថា វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង តម្រូវថា រឿងក្តីត្រូវបន្តទៅជំនុំជម្រះ ផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ[58]។

១៣. ***ទឡ្ហីករណ៍ផ្ទាល់មាត់ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី ២៧ ដល់ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩។*** នៅថ្ងៃទីបីនៃសវនាការ ចៅក្រម Olivier Beauvallet បានចោទសួរទៅ ស.ព.អ. "ពាក់ព័ន្ធនឹងការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នាក្នុងពេលតែមួយ"[59]។ ស.ព.អ. បានលើកទឡ្ហីករណ៍ថា ការចេញដីកាដំណោះស្រាយពីរ អាចត្រូវអនុញ្ញាតបាន ដោយសារតែ "ការផ្លាស់ប្តូរយន្តការខ្វែងយោបល់គ្នា ដែលបានអនុញ្ញាត ... ទៅជាយន្តការតម្រូវចាំបាច់" នឹងរំលោភបំពានទៅលើពាក្យពេចន៍ក្នុងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និង វិធានផ្ទៃក្នុង ហើយរឹតត្បិតដោយមិនត្រឹមត្រូវទៅលើឆន្ទានុសិទ្ធិឯករាជ្យរបស់ ស.ច.ស."[60]។ ទោះបីជាមេធាវីការពារក្តីបានយល់ស្របនឹង ស.ព.អ. នៅក្នុងបណ្តឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សររបស់ខ្លួនក្តី ក៏មេធាវីការពារក្តីបានស្នើ

---

[57] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៩ ឯកសារ D267/4 ("បណ្តឹងឧទ្ធរណ៍របស់ មាស មុត") កថាខណ្ឌ ៣៤-៤៨។ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៩ ឯកសារ D266/2 ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ.") កថាខណ្ឌ ១៩១-៩៨។

[58] បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ. កថាខណ្ឌ ១៩១-៩៨។

[59] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី ០០៣ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩ ឯកសារ D266/18.2 ម៉ោង ១១.២៤.៤០-១១.២៨.៣៥។

[60] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី ០០៣ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩ ឯកសារ D266/18.2 ម៉ោង ១១.២៨.៣៥-១១.៤០.៥៦។ *សូមមើលជាពិសេសដូចខាងលើ* នៅម៉ោង ១១.៣៤.៥៦-១១.៣៩.៤២។

សុំឱយពិចារណាថា ភាគីទាំងពីរអាចមានភាន់ច្រឡំ៖ "បើយើងខុស ហើយបើ [ស.ច.ស.] បំពេញកិច្ច *ហួសពីសមត្ថកិច្ច* នោះ គ្មានអ្វីអាចរារាំង [អ.ប.ជ.] មិនឱយបង្វិលបញ្ហាត្រឡប់មកវិញ ដោយបង្គាប់ឱយ ស.ច.ស. រួមបង្កើតឡើងវិញ និង ដោយមានការបង្គាប់ណែនាំឱយពួកគេត្រូវចេញដីកាមួយ ឬ ក៏តាមលទ្ធភាពសម្រាប់ [អ.ប.ជ.] ដែលត្រូវចាត់ចែងដោយ [ខ្លួនឯងផ្ទាល់]"[61]។

១៤. ***អ.ប.ជ. ចេញសេចក្តីពិចារណារបស់ខ្លួនក្នុងរឿងក្តី ០០៤/២។*** នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៩ មុនពេលសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍ខ្វែងក្នុងរឿងក្តី ០០៣ អ.ប.ជ. បានចេញសេចក្តីពិចារណារបស់ខ្លួនក្នុងរឿងក្តី ០០៤/២ ដោយប្រកាសថា "ការចេញដីកាដំណោះស្រាយពីរ គឺខុសច្បាប់ ហើយរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក."[62]។ បើទោះជាយ៉ាងនេះក្តី ចៅក្រមជាតិ និង ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានពិនិត្យអង្គសេចក្តីឡើងវិញ និង ផ្តល់ការគាំទ្រដល់ដីកាដំណោះស្រាយតាមការជ្រើសរើសរបស់ពួកគាត់[63]។

១៥. ***អ.ប.ជ. ចេញសេចក្តីណែនាំផ្ទុយគ្នា។*** នៅវាងនៃការខ្វែងយោបល់គ្នាដែលកើតមានក្រោយៗមកក្នុងរឿងក្តី ០០៤/២ ចៅក្រមនៃ អ.ប.ជ. បានចេញអនុស្សរណៈផ្ទុយគ្នាស្តីពីអនុភាពផ្លូវច្បាប់លើសេចក្តីពិចារណារបស់ខ្លួន៖

ក. នៅថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២០ ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន អ.ប.ជ. បានចេញអនុស្សរណៈអន្តរការិយាល័យមួយ ដោយថ្លែងថា មានតែសំអាងហេតុ និង ការចាត់ចែងរួមគ្នាទេ ទើបមានអនុភាពផ្លូវច្បាប់ ហើយថា ការជូនដំណឹងអំពីសេចក្តីពិចារណាទៅដល់ អ.ជ.ស.ដ. "គឺរំលោភបំពានទៅលើសេចក្តីសម្រេចជាឯកច្ឆន្ទរបស់ អ.ប.ជ."[64]។

ខ. នៅថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២០ ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានឆ្លើយតបថា ប្រធានចៅក្រមមិនមានសិទ្ធិអំណាចបង្គាប់ណែនាំទៅផ្នែកគ្រប់គ្រងតុលាការឡើយ ដោយការកត់

---

[61] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី ០០៣ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១៩ ឯកសារ D266/18.2 ម៉ោង ១២.០១.៣៤-១២.០៤.១៤។

[62] សេចក្តីពិចារណារបស់ អ.ជ.ប. ក្នុងរឿងក្តី ០០៤/២ ទំព័រ ៨៩។

[63] *ដូចខាងលើ* ទំព័រ ៨៩។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ២៧៣-៣០២, ៣០៤-៦៨៧, ទំព័រ ៣៨២។

[64] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៦០) អនុស្សរណៈរបស់អង្គបុរេជំនុំជម្រះ ចំណងជើងថា "ការបញ្ជាក់បំភ្លឺលើសេចក្តីសម្រេចនៅក្នុងរឿងក្តី ០០៤/២" ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២០ ឯកសារ D359/34 ទំព័រ ២។

សម្គាល់ថា ផ្នែកគ្រប់គ្រងតុលាការបានទទួលសេចក្តីណែនាំផ្ទុយគ្នាពីក្រឡាបញ្ជីជាតិ និង ក្រឡាបញ្ជីអន្តរជាតិនៃ អ.ប.ជ. - រៀងៗខ្លួន ឱយបញ្ចូលរឿងក្តីទៅក្នុងបណ្ណសារ និង ឱយជូនដំណឹងទៅ អ.ជ.ស.ដ. អំពីសេចក្តីពិចារណារបស់ អ.ប.ជ.[65]។

គ. នៅថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០២០ ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានទទូចថា ចម្លើយនៅថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២០ របស់ពួកគាត់ គឺជា "ការបញ្ជាក់បំភ្លឺពីសិទ្ធិអំណាចជាផ្លូវការ" ដែលស្វែងរកដោយការិយាល័យរដ្ឋបាល ដោយថ្លែងថា៖ "បើការិយាល័យរដ្ឋបាលនៅតែមានៈនៅក្នុងអសកម្មភាពទៅទៀត ដោយគ្មានមូលដ្ឋានផ្លូវច្បាប់ នោះការរៀបចំនៃសមាសភាពនៃ [ក.ស.ច.ស.] ឡើងវិញ គួរត្រូវលើកមកពិចារណា ដោយភាគីពាក់ព័ន្ធសម្រាប់ដំណើរការនីតិវិធី ដូចមានចែងក្នុងវិធាន៦៩(២)(ក) នៃវិធានផ្ទៃក្នុង" [66]។ និង

ឃ. នៅថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០២០ ប្រធាន អ.ប.ជ. បានថ្លែងថា អ.ប.ជ. "បានបំពេញករណីកិច្ចរបស់ខ្លួនរួចរាល់ អនុលោមតាមច្បាប់ ហើយមិនតម្រូវឱយបំពេញកិច្ចរដ្ឋបាលណាមួយឡើយ" ដោយបញ្ជាក់ម្តងទៀតអំពីគោលជំហររបស់ខ្លួននៅក្នុងអនុស្សរណៈថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២០ ដែលថា មានតែសំអាងហេតុ និង ការចាត់ចែងរួមគ្នាទេ ទើបមានអនុភាពផ្លូវច្បាប់[67]។

១៦. ***លោក មាស មុត ស្នើសុំការបញ្ជាក់បំភ្លឺ***។ នៅថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២០ ដោយសារតែការជាប់គាំងផ្នែកនីតិវិធីនៅក្នុងរឿងក្តី ០០៤/០២ មេធាវីការពារក្តី បានស្នើសុំការបញ្ជាក់បំភ្លឺអំពីមូលដ្ឋានផ្លូវច្បាប់ ដែលចៅក្រមនៃ អ.ប.ជ. បានពិចារណាដាច់ដោយឡែកពីគ្នាលើអង្គសេចក្តីនៃដីកាដំណោះស្រាយខុសច្បាប់ ដែលបានជំទាស់មិនឱយបង្វិលសំណុំរឿងទៅ ស.ច.ស. ដោយមានការបង្គាប់ណែនាំឱយចេញដីកាដំណោះស្រាយមួយ ឬ ពិនិត្យសំណុំរឿងឡើងវិញដោយខ្លួនឯង ហើយចេញ

---

[65] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៦០) អនុស្សរណៈរបស់អង្គបុរេជំនុំជម្រះ ចំណងជើងថា "ការជូនដំណឹងអំពីសេចក្តីពិចារណារបស់ អ.ជ.ប. នៅក្នុងរឿងក្តី ០០៤/២" ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០២០ ឯកសារ D359/35 ទំព័រ ៥។

[66] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៦០) អនុស្សរណៈរបស់អង្គបុរេជំនុំជម្រះ ចំណងជើងថា "ការបញ្ជូនសំណុំរឿង ០០៤/២" ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០២០ ឯកសារ D359/36 កថាខណ្ឌ ៣៧។

[67] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៦០) អនុស្សរណៈរបស់អង្គបុរេជំនុំជម្រះ ចំណងជើងថា "ការបញ្ជាក់សាជាថ្មីលើសេចក្តីសម្រេចលើសំណុំរឿង ០០៤/២" ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០២០ ឯកសារ D359/37 ទំព័រ ២។

ដីកាដំណោះស្រាយផ្ទាល់ខ្លួន[68]។ ក្រៅពីការចោទសួរពីមូលដ្ឋានផ្លូវច្បាប់ពាក់ព័ន្ធនឹងថា តើ "គោលចំហរដើម" ដែលបម្រុងទុកសម្រាប់ការខ្វែងយោបល់គ្នារវាង ស.ច.ស. នៅក្នុងអំឡុងពេលស៊ើបអង្កេតរបស់ពួកគាត់ អាចអនុវត្តដោយរបៀបណា ដើម្បីដោះស្រាយចំពោះការចេញដីកាដំណោះស្រាយពីរដែលខុសច្បាប់នោះ[69] មេធាវីការពារក្តីបានស្នើសុំការបញ្ជាក់បំភ្លឺទៅលើ[70]៖

ក. ថាតើ ស.ច.ស. បានគោរពតាមពាក្យពេចន៍ និងស្មារតីនៃកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. វិធានផ្ទៃក្នុង និងយុត្តិសាស្ត្ររបស់ អ.ប.ជ. ឬទេ ក្នុងការចេញដីកាដំណោះស្រាយដាច់ដោយឡែក និងផ្ទុយគ្នាទាំងនេះ។

ខ. ថាតើ ទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង ដីកាសម្រេចលើកលែងចោទប្រកាន់ មិនអាចមានសុពលភាពឬទេ ដោយសារតែដីកាទាំងពីរត្រូវបានចេញដោយរំលោភទៅលើវិធាន ៦៧ (១) នៃវិធានផ្ទៃក្នុង។

គ. ថាតើ អ.ប.ជ. បានពិចារណា ដោយយោងវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង ឬទេ ដើម្បីកំណត់ពីផលវិបាកនៃការប្រកាសថា ការចេញដីកាដំណោះស្រាយដាច់ដោយឡែក និងផ្ទុយគ្នាទាំងនេះ គឺជាការខុសច្បាប់។

ឃ. ថាតើ អ.ប.ជ. ខកខានមិនបានអនុវត្តអ្វីដែលខ្លួនពិចារណាថា ជាច្បាប់ដែលអាចអនុវត្តបានឬទេ ដោយការមិនបានបង្វិលដីកាដំណោះស្រាយទាំងនេះទៅ ស.ច.ស. វិញ ដោយមានការបង្គាប់ណែនាំ និង ដោយការមិនបានពិនិត្យសំណុំរឿងឡើងវិញដោយខ្លួនឯងនោះ។

ង. ថាតើចៅក្រមនៃ អ.ប.ជ. ត្រូវបានតម្រូវឱយបំពេញកិច្ចរួមគ្នាជាសហសេវិកឬទេ នៅក្នុងការពិនិត្យសំណុំរឿងឡើងវិញ កាលបើពួកគេជ្រើសរើសមិនបង្វិលដីកាដំណោះស្រាយទៅ ស.ច.ស. វិញ។

---

[68] សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/០២ ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០២០ ឯកសារ D267/24 ("សំណើសុំការបញ្ជាក់បំភ្លឺ") កថាខណ្ឌ ១៥។

[69] *ដូចខាងលើ* កថាខណ្ឌ ៣៧។

[70] *ដូចខាងលើ* កថាខណ្ឌ ១៧, ១៩, ២១, ២៣, ២៥, ២៧, ២៨, ៣១, ៣៣, ៣៥, ៣៩។

ច. ថាតើ អ.ប.ជ. គួរបានធានាឱយកាន់តែប្រសើរនូវសច្ចភាពផ្លូវច្បាប់ និង តម្លាភាពឬទេ ដោយការបង្វិលសំណុំរឿងទៅ ស.ច.ស. វិញ ដោយមានការបង្គាប់ណែនាំ ឬ ក៏ដោយការពិនិត្យសំណុំរឿងឡើងវិញដោយខ្លួនឯង។

ឆ. ថាតើ អ.ប.ជ. មានកាតព្វកិច្ចត្រូវផ្តល់សេចក្តីសម្រេចជាឯកច្ឆ័ន្ទ ទៅលើអនុភាពផ្លូវច្បាប់នៃការចេញដីកាដំណោះស្រាយខុសច្បាប់ទាំងនេះ ដើម្បីធានាដល់សច្ចភាពផ្លូវច្បាប់។

ជ. ថាតើសំអាងផ្លូវច្បាប់ ដែលចៅក្រមជាតិនៃ អ.ប.ជ. បានអនុវត្ត ដើម្បីសឱយឃើញថាត្រឹមត្រូវសម្រាប់ការត្រួតពិនិត្យដីកាដំណោះស្រាយដែលខុសច្បាប់ទាំងនេះ។

ឈ. ថាតើចៅក្រមជាតិនៃ អ.ប.ជ. ពិចារណាដីកាសម្រេចលើកលែងចោទប្រកាន់ ជាមូលដ្ឋានត្រឹមត្រូវតាមច្បាប់ ដើម្បីរំលត់រឿងក្តី ឬទេ នៅពេលដែល អ.ប.ជ. សម្រេចជាឯកច្ឆ័ន្ទថា ស.ច.ស. បានរំលោភបំពានលើក្របខណ្ឌ អ.វ.ត.ក.។

ញ. ថាតើចៅក្រមជាតិនៃ អ.ប.ជ. បានងាកទៅប្រើគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ*ឬទេ បន្ទាប់ពីបានអនុវត្តវិធានបកស្រាយតាមប្រព័ន្ធច្បាប់ស៊ីវិលទៅលើវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង ដើម្បីដោះស្រាយការចេញដីកាដំណោះស្រាយខុសច្បាប់ទាំងពីរនេះ។ និង

ដ. ថាតើ អ.ជ.ស.ដ. អាចត្រូវបានប្តឹងឱយទទួលយកដីកាបញ្ជូនទៅជំនុំជម្រះមួយដែលខុសច្បាប់ ដោយមានវិការៈនីតិវិធី តាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ឬទេ។

១៧. ***អ.ជ.ស.ដ. បដិសេធមិនទទួលពិនិត្យរឿងក្តី ០០៤/២។*** បន្ទាប់ពី ស.ព.អ. ស្នើឱយ អ.ជ.ស.ដ. បន្តនីតិវិធីក្នុងការបញ្ជូនរឿងក្តី ០០៤/២ ទៅជំនុំជម្រះ ចៅក្រមនៃ អ.ជ.ស.ដ. បានចេញសេចក្តីប្រកាសព័ត៌មាននៅថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០២០ ដោយថ្លែងថា ពួកគាត់មិនអាចយល់ស្របគ្នាលើសំអាងហេតុរួមទេ។ ចៅក្រមជាតិនៃ អ.ជ.ស.ដ. យល់ឃើញថា អ.ជ.ស.ដ. ពុំមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចណាមួយឡើយ ដោយសារតែអង្គជំនុំជម្រះមិនមានសិទ្ធិចូលមើលសំណុំរឿង ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ អ.ប.ជ. និង ដោយសាររឿងក្តីនេះត្រូវបានបិទនៅចំពោះមុខ

អ.ប.ជ. តាមសេចក្តីពិចារណារបស់ អ.ប.ជ.[71]។ ចៅក្រមអន្តរជាតិនៃ អ.ជ.ស.ដ. បានពិចារណាថា អ.ជ.ស.ដ. "មាន*សិទ្ធិអំណាចពិសេស* ក្នុងការដោះស្រាយបញ្ហាបថមៗ ដែលភាគីបានលើកឡើង..."។ ដោយសារតែ អ.ជ.ស.ដ. មិនអាចសម្រេចបានសំឡេងភាគច្រើនលើសលុបនោះ "ការចេញសេចក្តីសម្រេចជាផ្លូវការមួយ ... មិនអាចធ្វើទៅបានឡើយ"[72]។

១៨. ***លោក មាស មុត ស្នើដាក់សារណាបន្ថែមទៅលើបណ្តឹងឧទ្ធរណ៍របស់គាត់។*** បន្ទាប់ពីមានសេចក្តីប្រកាសព័ត៌មានរបស់ អ.ជ.ស.ដ. មេធាវីការពារក្តីបានស្នើសុំដាក់សារណាបន្ថែមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ខ្លួន ដោយសារតែសេចក្តីថ្លែងការណ៍របស់ អ.ជ.ស.ដ. បានលើកឡើងអំពីលទ្ធភាពនៃការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមិនអាចជំទាស់បាន តាមលងបន្លាចលោក មាស មុត ជារៀងរហូត[73]។ មេធាវីការពារក្តីស្នើសុំពិចារណាឱយថា អ.ប.ជ. ដោយគោរពតាមប្រណិធាន និង ទំនួលខុសត្រូវរបស់ខ្លួន ក្នុងការធានាពីភាពត្រឹមត្រូវនៃដំណើរការនីតិវិធី ត្រូវតែផ្អាកដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ វៀរលែងតែ អ.ប.ជ. ព្រមព្រៀងគ្នាលើវិវឌ្ឍនាការនៃរឿងក្តី ០០៣[74]។

១៩. ***ស.ព.អ. ប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីប្រកាសព័ត៌មានរបស់ អ.ជ.ស.ដ. នៅក្នុងរឿងក្តី ០០៤/២។*** ដោយការអះអាងពីអសកម្មភាពរបស់ អ.ជ.ស.ដ. និង សេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០២០ បង្កើតបានជា "សេចក្តីសម្រេច" មួយ ដែលបញ្ចប់រឿងក្តីនេះយ៉ាងមានប្រសិទ្ធភាព ស.ព.អ. បានប្តឹងសាទុក្ខទៅកាន់ អ.ជ.ត.ក. នៅថ្ងៃទី ៤ ខែឧសភា ឆ្នាំ ២០២០[75]។ ស.ព.អ. បានលើកទឡ្ហីករណ៍ថា អ.ជ.ស.ដ. ខកខានមិនបានផ្តល់អនុភាពទៅលើគោលជំហរ "ដើម" ខកខានមិនបានសំអាងលើអំណាចដែលមានជាប់មកជាមួយ ក្នុងការប្រកាសពីបញ្ហានៃភាពត្រឹមត្រូវតាមច្បាប់

---

[71] សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក.៖ *សេចក្តីថ្លែងការណ៍របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. ស្តីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន* ចុះថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០២០ គេហទំព័រ https://eccc.gov.kh/ en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao ("សេចក្តីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ០០៤/២")។

[72] *ដូចខាងលើ*។

[73] សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ ២០២០ ឯកសារ D267/27 ("សារណាបន្ថែមរបស់ មាស មុត") កថាខណ្ឌ ២៤។

[74] *ដូចខាងលើ* កថាខណ្ឌ ៤៤-៥២។

[75] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-២០០៩-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៤ ខែឧសភា ឆ្នាំ ២០២០ ឯកសារ E004/2/1 កថាខណ្ឌ ៤២។

បានដាក់លក្ខខណ្ឌតម្រូវផ្នែករដ្ឋបាលបន្ថែមដោយចិត្តឯង ទៅលើការជូនដំណឹងជាផ្លូវការអំពីសេចក្តីពិចារណារបស់ អ.ប.ជ. និង បានរំលត់រឿងក្តីនេះយ៉ាងមានប្រសិទ្ធភាព ដោយផ្អែកលើមូលដ្ឋានដែលមិនត្រូវបានអនុញ្ញាតឱយ[76]។

២០. ***លោក មាស មុត ស្នើសុំធ្វើអន្តរាគមន៍នៅក្នុងរឿងក្តី ០០៤/២។*** ដោយសារតែសេចក្តីសម្រេចរបស់ អ.ជ.ត.ក. នៅក្នុងរឿងក្តី ០០៤/២ អាចនឹងប៉ះពាល់ជាទូទៅដល់ដំណើរការនីតិវិធីនៅក្នុងរឿងក្តី ០០៣ មេធាវីការពារក្តីបានស្នើសុំធ្វើអន្តរាគមន៍នៅក្នុងរឿងក្តី ០០៤/២ ដើម្បីបង្ហាញពី[77]៖

ក. ហេតុដែល អ.ជ.ស.ដ. មិនបានទទួលពិនិត្យសំណុំរឿងនេះ ដោយសារតែពុំមានដីកាដំណោះស្រាយដែលមានសុពលភាព។

ខ. ហេតុដែល សេចក្តីប្រកាសព័ត៌មាន នៅថ្ងៃទី ៣ ខែមេសា ឆ្នាំ ២០២០ ភាពអសកម្ម និង ការបញ្ជូនត្រឡប់វិញនូវសារណាសុំការពិចារណារបស់ ស.ព.អ. ពុំមែនជាសេចក្តីសម្រេច ដែលមានអនុភាពបញ្ចប់ដំណើរការនីតិវិធីទេ "ដែលអាចប្តឹងសាទុក្ខ"។

គ. ហេតុដែល អ.ប.ជ. កំពុងមានសំណុំរឿងក្តី ០០៤/២ នៅក្នុងដៃ ហេតុដូច្នេះហើយ ទើប អ.ជ.ត.ក. ពុំចាំបាច់អនុវត្តអំណាចរបស់ខ្លួនដែលជាប់ជាមួយនោះទេ។

ឃ. ហេតុដែល គោលជំហរ "ដើម" នៅក្នុងកិច្ចព្រមព្រៀង និង ក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ដែលចែងថា "ការស៊ើបអង្កេតត្រូវបន្តទៅមុខ" កាលណាសហព្រះរាជអាជ្ញា ឬ ស.ច.ស. ខ្វែងយោបល់គ្នា *អនុវត្តតែនៅក្នុងដំណាក់កាលស៊ើបអង្កេតប៉ុណ្ណោះ*។

ង. ហេតុដែល ទោះបីវិធាន ៧៧(១៣)(ខ) ត្រូវបានចាត់ទុកជា *ច្បាប់ពិសេស ដូច* វិធាន ៧៧(១៣)(ក) ក្តី ក៏វិធានទាំងពីរត្រូវបានរៀបចំឡើង សម្រាប់ការចេញដីកាដំណោះស្រាយតែ

---

[76] *ដូចខាងលើ* កថាខណ្ឌ ៤៣។

[77] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-២០០៩-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក សំណើរបស់ មាស មុត សុំធ្វើអន្តរាគមន៍ និង ឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០២០ ឯកសារ E004/2/2 ("សំណើសុំធ្វើអន្តរាគមន៍របស់ មាស មុត") កថាខណ្ឌ ១១-១២។

មួយ ហើយ អ.ប.ជ. បានសម្រេចជាឯកច្ឆ័ន្ទថា ដីកាដំណោះស្រាយទាំងពីរត្រូវបានចេញដោយខុសច្បាប់។

ច. ហេតុដែល វិធាន ៧៩(១) ក៏ត្រូវបានរៀបចំឡើងសម្រាប់ដីកាដំណោះស្រាយតែមួយ ហើយពុំមានន័យថា អ.ជ.ស.ដ. អាចត្រូវបានប្តឹងសុំឱ្យទទួលពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានចេញដោយខុសច្បាប់នោះទេ។ និង

ឆ. ហេតុដែល ភាគីទាំងឡាយនៃកិច្ចព្រមព្រៀង និង អ្នកព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ពុំយល់ស្របគ្នា ក្នុងការបញ្ជូនរឿងក្តីទៅជំនុំជម្រះ នៅពេលដែល ស.ច.ស. ចេញដីកាដំណោះស្រាយដាច់ដោយឡែក និងផ្ទុយគ្នានោះទេ។

២១. អ.ជ.ត.ក. បានបដិសេធសំណើសុំធ្វើអន្តរាគមន៍របស់មេធាវីការពារក្តី នៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២០[78]។

២២. ***អ.ជ.ត.ក. បញ្ចប់រឿងក្តី ០០៤/២។*** នៅថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០២០ អ.ជ.ត.ក. បានបញ្ចប់រឿងក្តី ០០៤/២[79] ដោយសម្រេចថា នៅពេលដែល អ.ប.ជ. បានប្រកាសជាឯកច្ឆ័ន្ទថា ស.ច.ស. បានបំពេញកិច្ចដោយខុសច្បាប់ នោះ ដីកាដំណោះស្រាយទាំងនេះត្រូវចាត់ទុកជាមោឃៈ ហើយវាមិនពាក់ព័ន្ធទេដែលថា អ.ប.ជ. មិនទទួលបានសំឡេងភាគច្រើនលើសលុបលើអង្គសេចក្តីនៃបណ្តឹងសាទុក្ខរបស់ភាគីនោះទេ[80]។ *"កិច្ចដែលគ្មានសុពលភាព មិនអាចបង្កើតផលវិបាក ឬ លទ្ធផលត្រឹមត្រូវតាមច្បាប់ទេ។ អាស្រ័យហេតុនេះ ជាការសមហេតុផលដែលថា ចំណាត់ការប្រភពដើម ដែលជាដីកាដំណោះស្រាយនីមួយៗនោះ ពុំមានអនុភាពផ្លូវច្បាប់ទេ"*[81]។ ទោះបីមានការយល់ឃើញថា

---

[78] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-២០០៩-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំការអនុញ្ញាតចូលធ្វើអន្តរាគមន៍ និងឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិលើអនុភាព ដែលនាំឱ្យបញ្ចប់សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២០ ឯកសារ E004/2/2/1។

[79] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អនុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០២០ ឯកសារ E004/2/1/1/2 ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២")។

[80] *ដូចខាងលើ* កថាខណ្ឌ ៥៣។

[81] *ដូចខាងលើ* កថាខណ្ឌ ៦៧។

គោលដៅនៃយន្តការដោះស្រាយការខ្វែងយោបល់គ្នា គឺត្រូវ "ទប់ស្កាត់ភាពទាល់ច្រកមិនឱយរាំង ដំណើរការនីតិវិធីបន្តដំណើរការទៅរកការជំនុំជម្រះ"គ្គី ក៏អ.ជ.ត.ក. បានសម្រេចដោយ"ឥតច្រឡំ" ថា "រឿងក្ដីមួយមិនអាចឈានទៅជំនុំជម្រះឡើយ កាលណាគ្មានដីកាដំណោះស្រាយសុពល"[82]។

២៣. ដោយកត់សម្គាល់ថា ការយល់ឃើញរបស់ អ.ប.ជ. ដែលថា វិធាន ៧៩(១) ណែនាំថា អ.ប.ជ. "មានសិទ្ធិអំណាចក្នុងការចេញដីកាដំណោះស្រាយថ្មី ឬ កែប្រែដីកាដំណោះស្រាយ" និងថា "ការបំពេញតួនាទីសភាស៊ើបសួរកម្ពុជានៅ អ.វ.ត.ក." អ.ប.ជ. ត្រូវស៊ើបអង្កេតរឿងក្ដីដោយខ្លួនឯង នៅពេលបានទទួលពិនិត្យដីកាលើកលែងចោទប្រកាន់ អ.ជ.ត.ក. ពិចារណាថា ការយល់ឃើញទាំងនេះ "នឹងនាំអ្នកវិភាគសមហេតុផល អាចសន្និដ្ឋានបានថា [អ.ប.ជ.] បានដឹងអំពីសិទ្ធិអំណាចរបស់ខ្លួនក្នុងការធ្វើលើសពីការប្រកាសភាពខុសច្បាប់នៃស្ថានការណ៍ ដែលពាក់ព័ន្ធទៅនឹងការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និង ចេញដីកាដំណោះស្រាយសុពលភាពរបស់ខ្លួនផ្ទាល់"[83]។ អ.ជ.ត.ក. យល់ឃើញថា អ.ប.ជ. "គប្បីចាប់យកមួយជំហានបន្ថែមទៀត និង ផ្ដល់នូវការសម្រេចស្ថាពរពិតជាក់ស្ដែង"[84]។

២៤. ដោយពិចារណាឃើញថា ការខ្វែងយោបល់គ្នារបស់ ស.ច.ស. "បានសម្រេចយ៉ាងតឹងតែង" ដែលមិនអាចសម្របសម្រួល បាននាំឱយ ស.ច.ស. ចុះកំណត់ហេតុការខ្វែងយោបល់គ្នា និង ជៀសពុំរួចពីការចេញដីកាដំណោះស្រាយដាច់ដោយឡែកនិងផ្ទុយគ្នា[85] ដែលថា"ស.ព.អ. បានកំពុងធ្វើចំណាត់ការដោយពុំមានការគាំទ្រ (ឬ ជំទាស់) ពី ស.ព.ជ."[86] និងថា "ពុំមានការស្រុះស្រួលគ្នា បន្ទាប់ពីរយៈពេលដប់បីឆ្នាំនៃកិច្ចស៊ើបសួរ ដែលថា អោ អាន ស្ថិតក្នុងយុត្តាធិការរបស់តុលាការ" អ.ជ.ត.ក. បានយល់ឃើញថា ក្នុងករណីពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចអនុវត្តបាន នោះរឿងក្ដី ០០៤/២ គប្បីត្រូវបញ្ចប់[87]។

---

[82] *ដូចខាងលើ* កថាខណ្ឌ ៦៨។

[83] *ដូចខាងលើ* កថាខណ្ឌ ៦១ ដោយដកស្រង់ *ក្នុងចំណោមនោះ* សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៤/២ កថាខណ្ឌ ៣០។

[84] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្ដី ០០៤/២ កថាខណ្ឌ ៦១។

[85] *ដូចខាងលើ* កថាខណ្ឌ ៦២។

[86] *ដូចខាងលើ* កថាខណ្ឌ ៦៤។

[87] *ដូចខាងលើ* កថាខណ្ឌ ៦៩។

២៥. ***អ.ប.ជ. បដិសេធសំណើរបស់លោក មាស មុត សុំការបញ្ជាក់បំភ្លឺ។*** នៅថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០២០ អ.ប.ជ. បានបដិសេធសំណើរបស់លោក មាស មុត សុំការបញ្ជាក់បំភ្លឺ ដោយពិចារណាថា ការចេញសេចក្តីពិចារណា ឬ សេចក្តីសម្រេចរបស់ អ.ប.ជ. នៅក្នុងដំណើរការនីតិវិធីផ្សេងគ្នា "មិនមានអនុភាពដោយផ្ទាល់ទៅលើរឿងក្តីដែលមិនទាន់សម្រេចឡើយ" ទោះបីជាបានថ្លែងថា អ.ប.ជ. "មិនមែនមិនដឹងអំពីទម្លាកករណ៍ ដែលថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ អាចត្រូវបានយល់ច្រឡំនោះ"[88]។ ទោះបីជាមានអនុស្សរណៈផ្ទុយគ្នា ដែលកើតចេញពី អ.ប.ជ. ពាក់ព័ន្ធនឹងអនុភាពផ្លូវច្បាប់នៃសេចក្តីពិចារណាក្នុងរឿងក្តី ០០៤/២ របស់ខ្លួនក្តី ក៏អង្គជំនុំជម្រះបានយល់ឃើញថា "សេចក្តីពិចារណានេះបានផ្តល់នូវសច្ចភាពផ្លូវច្បាប់ និង តម្លាភាព ដែលបានតម្រូវសម្រាប់សេចក្តីសម្រេចរបស់តុលាការ ដែលកើតចេញពីអង្គជំនុំជម្រះ តាមកាលៈទេសៈជាក់លាក់នៃសំណុំរឿងនោះ"[89]។

២៦. ***អ.ប.ជ. បដិសេធសារណាបន្ថែមរបស់ លោក មាស មុត។*** អ.ប.ជ. បានបដិសេធសារណាបន្ថែមរបស់លោក មាស មុត នៅថ្ងៃតែមួយ ដែលអង្គជំនុំជម្រះបានបដិសេធសំណើសុំការបញ្ជាក់បំភ្លឺរបស់គាត់ ដោយយល់ឃើញថា សេចក្តីប្រកាសព័ត៌មានរបស់ អ.ជ.ស.ដ. នៅក្នុងរឿងក្តីមួយផ្សេងទៀត"មិនមានអនុភាពភ្លាមៗឬដោយផ្ទាល់លើរឿងក្តីដែលមិនទាន់សម្រេចនោះឡើយ"[90] ថាបណ្តឹងឧទ្ធរណ៍នានាត្រូវបានសង្ខេបជូនយ៉ាងលម្អិត និង ជជែកដេញដោលដោយផ្ទាល់មាត់[91] និងថា កាលៈទេសៈនេះមិនបានតម្រូវឱយមានការពឹងផ្អែកលើអំណាចដែលជាប់ជាមួយ (ថ្វីបើអង្គជំនុំជម្រះបានអះអាងបញ្ជាក់ឡើងវិញថា អង្គជំនុំជម្រះមានអំណាចដែលជាប់ជាមួយ ដើម្បីការពារដំណើរការគ្រប់គ្រងយុត្តិធម៌ឱយល្អ និង ត្រឹមត្រូវ)[92]។

---

[88] សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/២ ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០២០ ឯកសារ D266/24 និង D267/32 កថាខណ្ឌ ២៨។

[89] *ដូចខាងលើ* កថាខណ្ឌ ៣១។

[90] សេចក្តីសម្រេចលើសារណាបន្ថែមរបស់ មាស មុត ទៅលើបណ្តឹងឧទ្ធរណ៍របស់គាត់ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០២០ ឯកសារ D267/33 កថាខណ្ឌ ៣២។

[91] *ដូចខាងលើ* កថាខណ្ឌ ៣៣។

[92] *ដូចខាងលើ* កថាខណ្ឌ ៣៥។

២៧. ***អ.ប.ជ. ចេញសេចក្ដីពិចារណារបស់ខ្លួននៅក្នុងរឿងក្ដី ០០៣។*** នៅថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០២១ អស់រយៈពេល ១៦ ខែ បន្ទាប់ពីទទួលករណីផ្ទាល់មាត់ អ.ប.ជ. បានចេញសេចក្ដីពិចារណារបស់ខ្លួន នៅក្នុងរឿងក្ដី ០០៣ ដោយប្រើប្រាស់ និង បញ្ចូលសំអាងហេតុជាច្រើនរបស់ខ្លួនពីសេចក្ដីពិចារណា នៅក្នុងរឿងក្ដី ០០៤/២[93]។ "ដោយការចោទលទោសជាថ្មីម្ដងទៀត ទៅលើស្ថានការណ៍ដ៏អាក្រក់ ផ្នែកច្បាប់ ដែលសកម្មភាពខុសច្បាប់របស់ [ស.ច.ស.] បានបង្កើតឡើងចំពោះដំណើរការនីតិវិធី ផ្សេងទៀតរបស់ អ.វ.ត.ក."[94] អ.ប.ជ. ប្រកាសយ៉ាងជូរចត់ (ដូចក្នុងរឿងក្ដី ០០៤/២) ថា ស.ច.ស. បានបង្វែរដោយចេតនា និង ដោយគិតគូរច្បាស់លាស់នូវដំណើរការយុត្តិធម៌ ដោយសារ តែ "ពួកគាត់ប្រហែលជាមានចេតនាធ្វើឱយបរាជ័យដល់គោលជំហរដើម ហើយរំខានដល់សិទ្ធិ អំណាចរបស់ [អ.ប.ជ.]"[95] ដោយស្រុះស្រួលគ្នាក្នុងការចេញក្នុងពេលជាមួយគ្នា នូវដីកាដំណោះ ស្រាយដាច់ដោយឡែកនិងផ្ទុយគ្នា។

២៨. អ.ប.ជ. បានយល់ឃើញថា "កំហុសឆ្គងរបស់ ស.ច.ស. បានបង្កអន្តរាយដល់ប្រព័ន្ធទាំងមូល ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ" ហើយថា មិនគ្រាន់តែការ រំលោភបំពានទៅលើក្របខណ្ឌរបស់ អ.វ.ត.ក. ប៉ុណ្ណោះទេ "*ការអនុវត្តដោយខុសឆ្គង* [របស់ ស.ច.ស.] អាចមានតម្លៃស្មើនឹងការបដិសេធភាពអយុត្តិធម៌" ដោយសារតែ អ.ប.ជ. "មិនអាច បដិសេធថា ពួកគាត់ប្រហែលបានប៉ុនប៉ងធ្វើឱយបរាជ័យដល់គោលជំហរដើម និង ក្នុងការធ្វើ ឱយរសាយដល់សិទ្ធិអំណាចរបស់ អ.ប.ជ."[96]។

២៩. ការបកស្រាយ វិធាន ៦៧(១) ថាមានចែងយ៉ាងច្បាស់អំពីដីកាដំណោះស្រាយតែមួយ ដែល*ឬមួយ* ត្រូវចោទប្រកាន់ជនត្រូវចោទ *ឬក៏* ត្រូវរម្លត់សំណុំរឿងនោះ[97] អ.ប.ជ. បានយល់ឃើញថា ស.ច.ស. "បានប្រព្រឹត្តកំហុសលើអង្គច្បាប់ដ៏ធំធេង នៅក្នុងរឿងក្ដីនេះ ដោយការយល់ឃើញថា ក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក. អនុញ្ញាតឱយចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និង

---

93 *ប្រៀបធៀប* សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០២១ ឯកសារ D266/27 និង D267/35 ("សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣") កថាខណ្ឌ ៧៨-១០៩ *ជាមួយ* សេចក្ដីពិចារណា របស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៤/២ កថាខណ្ឌ ៩១-១២៥។

94 សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ១០៩។

95 *ដូចខាងលើ* កថាខណ្ឌ ១០៨។

96 *ដូចខាងលើ* កថាខណ្ឌ ១០៨។

97 *ដូចខាងលើ* កថាខណ្ឌ ១០៣។

ផ្ទុយគ្នា"[98] "[បាន]ធ្វើឱយអន្តរាយដល់មូលដ្ឋានគ្រឹះនៃប្រព័ន្ធចម្រុះ និង ដំណើរការត្រឹមត្រូវរបស់ អ.វ.ត.ក."[99] "បានដឹងពីការលំបាក ដែលចំណាត់ការរបស់ពួកគេអាចបង្កឱយមានឡើង មិនត្រឹមតែទៅលើបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះទេ តែហួសពីដំណាក់កាលបណ្តឹងឧទ្ធរណ៍ និង មុនដំណាក់កាលជំនុំជម្រះនៃដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ទៅទៀត"[100] ហើយថែមទាំងបានរារាំងដោយឥតខ្វល់ខ្វាយនឹងអនុវត្តភារកិច្ចតាមផ្លូវតុលាការរបស់ខ្លួន ក្នុងការសម្រេចសេចក្តីលើបញ្ហា ដែលបានប្តឹងមកខ្លួនឱយពិនិត្យទៅវិញ[101]។

៣០. អ.ប.ជ ក៏បានយល់ឃើញផងដែរថា វាជា "រឿងប្លែកៗ ដែលដីកាដំណោះស្រាយផ្ទុយគ្នា ត្រូវបានចេញក្នុងថ្ងៃតែមួយ ជាភាសាតែមួយ ដោយមានការប្រកាសរួមគ្នា ដោយ [ស.ច.ស.] ទាំងពីរនាក់ថា ពួកគាត់បានយល់ស្របគ្នាលើការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា"[102] និង ថា ស.ច.ស. បានផ្តល់ "សំអាងហេតុតិចតួចគួរឱយកត់សម្គាល់ ដោយលើកឡើងតែត្រឹមសេចក្តីសម្រេចកន្លងមករបស់ពួកគាត់ត្រឹមតែពីរប៉ុណ្ណោះ"[103]។ បន្តតាមផ្លូវដដែល អ.ប.ជ. យល់ថា "មិនត្រឹមតែជាឧទាហរណ៍ដាច់តែឯងប៉ុណ្ណោះទេ ប៉ុន្តែសកម្មភាពរបស់ពួកគាត់ [ស.ច.ស.] នៅក្នុងករណីនេះ គាំទ្រនូវទម្រង់មួយ ដែល [ស.ច.ស.] បានអនុម័តយកដោយច្បាស់លាស់ ក្នុងការដោះស្រាយបណ្តាសំណុំរឿងចុងក្រោយទាំងអស់ ក្នុងបញ្ជីសំណុំរឿងរបស់ អ.វ.ត.ក."[104] "[ការ] កត់សម្គាល់ដោយការសោកស្តាយថា តាមការយល់ដឹង និងបទពិសោធន៍របស់ខ្លួន មិនដែលធ្លាប់មានសំណុំរឿងព្រហ្មទណ្ឌណា នៅក្នុងប្រវត្តិសាស្ត្រនៃប្រព័ន្ធច្បាប់អន្តរជាតិ និង ប្រព័ន្ធច្បាប់ជាតិដទៃទៀត ដែលបញ្ចប់ដោយការចេញសេចក្តីសម្រេចផ្ទុយគ្នាចំនួនពីរ ក្នុងពេលដំណាលគ្នា ហើយចេញដោយការិយាល័យចៅក្រមតែមួយនោះទេ"[105]។

---

[98] *ដូចខាងលើ* កថាខណ្ឌ ៨៨។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១០៥ ដែល អ.ប.ជ. បានអះអាងថា ស.ច.ស. បានប្រព្រឹត្ត "កំហុសអង្គច្បាប់ធ្ងន់ធ្ងរ ដែលជាមូលដ្ឋាននៃសំអាងហេតុរបស់ពួកគេ"។

[99] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១០៦។

[100] *ដូចខាងលើ* កថាខណ្ឌ ១០៧។

[101] *ដូចខាងលើ* កថាខណ្ឌ ១០៥។

[102] *ដូចខាងលើ* កថាខណ្ឌ ១០៧។

[103] *ដូចខាងលើ* កថាខណ្ឌ ១០៦។

[104] *ដូចខាងលើ* កថាខណ្ឌ ១០៨។

[105] *ដូចខាងលើ* កថាខណ្ឌ ១០៩។

៣១. ទោះបីបានអះអាងបញ្ជាក់អំពីអំណាចរបស់ខ្លួនក្នុងការស៊ើបអង្កេត និង ចេញដីកាដំណោះស្រាយដែលកែប្រែក៏ដោយ ក៏ អ.ប.ជ. បានបដិសេធមិនអនុវត្តតាមសេចក្តីសម្រេចរបស់ អ.ជ.ត.ក. នៅក្នុងរឿងក្តី ០០៤/២ នោះទេ។ ដូចដែលពួកគាត់បានធ្វើនៅក្នុងរឿងក្តី ០០៤/២ ចៅក្រមនៃ អ.ប.ជ. បានបំបែកទៅជាភាគីជាតិ និង ភាគីអន្តរជាតិរៀង១ខ្លួន ដើម្បីផ្តល់ការគាំទ្រដល់ដីកាដំណោះស្រាយ តាមការជ្រើសរើសរបស់ពួកគាត់[106]។

៣២. ទោះបីជាប្រើប្រាស់ស្នៀតផ្សេង ក្រៅពីយោបល់ដាច់ដោយឡែករបស់ពួកគាត់ នៅក្នុងសំណុំរឿង ០០៤/២ ក្តី ក៏ចៅក្រមជាតិនៃ អ.ប.ជ. បានយល់ឃើញស្រដៀងគ្នាផងដែរថា សំណុំរឿង ០០៣ "គប្បីតម្កល់ទុកនៅបណ្ណសារនៃ អ.វ.ត.ក."[107]។ ពួកគាត់បានផ្តល់សំអាងហេតុថា អ.ប.ជ. មិនអាចអនុវត្តយន្តការដោះស្រាយជម្លោះនៅក្នុងវិធាន ៧២ បានទេ ដោយសារតែ ស.ច.ស. បានស្រុះស្រួលគ្នាមិនបញ្ជូនការខ្វែងយោបល់របស់ខ្លួនមក អ.ប.ជ. "ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា ត្រូវតម្កល់ទុកជាបានការដូចគ្នា មានសុពលភាពដូចគ្នា"[108] ដោយផ្អែកតាមវិធាន ៧៧(១៣) ស.ច.ស. មានឋានៈស្មើគ្នា ហើយដោយយោងទៅតាមគោលការណ៍សច្ចធារណ៍នៃនិរទោស "ច្បាប់ពុំអនុញ្ញាតឱយ អ.ជ.ប. សម្រេចថា កិច្ចរបស់ [ស.ច.ស.] ណាម្នាក់មានឧត្តមភាពនោះទេ"[109] ហើយ "ដូច្នេះ ដីកាដំណោះស្រាយទាំងពីររក្សាបាននូវតម្លៃស្មើគ្នាដដែល"[110]។

៣៣. ប្រហែលគ្នានឹងគោលជំហរនៅក្នុងរឿងក្តី ០០៤/២ ដែរ បើទោះបីជាបានប្រកាសអំពីចេតនាអាក្រក់ និង កំហុសឆ្គងដែលមិនសមស្របក្តី បើទោះបីជាបានថ្កោលទោសចំពោះការព្រមព្រៀងគ្នារបស់ ស.ច.ស.អ. ក្នុងការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ ក្នុងពេលជាមួយនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សមភាគីជាតិរបស់គាត់ក្តី និង បើទោះបីជាបានប្រកាសថាការចេញដីកាដំណោះស្រាយពីរ គឺជាការខុសច្បាប់ក្តី ក៏ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានប្រកាសថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ. មានសុពលភាព ហើយដីកាសម្រេចលើកលែង

---

[106] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១១១-១៨, ១១៩-៣៥៨។

[107] *ដូចខាងលើ* កថាខណ្ឌ ១១៨។

[108] ហាក់ដូចជាមានការខុសគ្នាក្នុងការបកប្រែនៅក្នុងកថាខណ្ឌ ១១៥។ វាគួរអានថា "ដីកាដំណោះស្រាយទាំងពីរមានតម្លៃដូចគ្នា និង មានសុពលភាពដូចគ្នា"។ (ការបកប្រែក្រៅផ្លូវការ)។

[109] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១១៣-១៦។

[110] *ដូចខាងលើ* កថាខណ្ឌ ១១៧។

ចោទប្រកាន់របស់ ស.ច.ស.ជ. *ហួសពីសមត្ថកិច្ច*[111]។ ទោះបីជាមានពាក្យពេចន៍បែបឆន្ទានុសិទ្ធិនៅក្នុងវិធាន ៧២(២) ក្តី ក៏ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានផ្តល់សំអាងហេតុថា ស.ច.ស. តម្រូវឱយងាកទៅរកយន្តការដោះស្រាយជម្លោះ មុនពេលចេញដីកាដំណោះស្រាយ[112] ដោយបានប្រកាសថា "គោលការណ៍នៃការបន្តស៊ើបអង្កេតតាមផ្លូវតុលាការនេះ គ្រប់គ្រងលើបញ្ហាដែលនៅចំពោះមុខនេះ"[113]។

៣៤. សេចក្តីសម្រេចពីសុពលភាពនៃដីកាដំណោះស្រាយនីមួយៗ ចៅក្រមអន្តរជាតិនៃ អ.ប.ជ. ទោះជាយល់ឃើញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាពក្តី ក៏បានយល់ឃើញថា ស.ច.ស.អ.៖

ក. តាមតែអំពើចិត្ត បានប្រតិបត្តិតាមសេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរតាមវិធាន ៦៦(១) ដោយដកហូតពីភាគីនានានូវរយៈពេល ១៥ ថ្ងៃ ក្នុងការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ[114]។

ខ. មិនយកចិត្តទុកដាក់ក្នុងការប្រស្រ័យទាក់ទងសំណុំរឿង និង បានបង្កើតឱយមានការពន្យាពេលហួសហេតុ ដោយរង់ចាំអស់រយៈពេលពីរខែ បន្ទាប់ពីការចេញសេចក្តីជូនដំណឹងលើកទីពីរតាមវិធាន ៦៦(១) ទើបបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញា[115]។

គ. ខកខានមិនបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ខ្លួននៅក្នុងរយៈពេលសមស្រប[116]។

ឃ. ដោយខុសឆ្គង "[បាន]តម្កល់គោលការណ៍កំណត់ប្រភេទនៃភ័ស្តុតាងតាមឋានានុក្រម និងតាមទម្រង់ច្បាប់ ដោយផ្អែកលើប្រភព ជាជាងលើខ្លឹមសារ"[117]។ និង

ង. ខកខានមិនបានបង្គាប់ឱយឃុំខ្លួនលោក មាស មុត មុនពេលជំនុំជម្រះ[118]។

[111] *ដូចខាងលើ* កថាខណ្ឌ ២៥៩។
[112] *ដូចខាងលើ* កថាខណ្ឌ ២៥៦-៥៨។
[113] *ដូចខាងលើ* កថាខណ្ឌ ២៥៦។
[114] *ដូចខាងលើ* កថាខណ្ឌ ១៣៩-៤១។
[115] សេចក្តីពិចារណារបស់ អ.ប.ជ ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១៤២-៤៣។
[116] *ដូចខាងលើ* កថាខណ្ឌ ១៣០។
[117] *ដូចខាងលើ* កថាខណ្ឌ ១៥៦។
[118] *ដូចខាងលើ* កថាខណ្ឌ ៣៤៥-៥៨។

៣៥. ពាក់ព័ន្ធនឹង ស.ច.ស.ជ. ចៅក្រមអន្តរជាតិនៃ អ.ប.ជ. បានយល់ឃើញថា ដីកាសម្រេចលើកលែងចោទប្រកាន់ "ជាការព្យាយាមមួយ ដើម្បីគេចចេញពីនីតិវិធីដែលតម្រូវចាំបាច់ សម្រាប់ការខ្វែងយោបល់គ្នា" គឺ "ជាការព្យាយាមដោយឥតអៀនខ្មាស់ក្នុងការគេចវេសទាំងស្រុង ពីលក្ខខណ្ឌតម្រូវជាចាំបាច់ និងសំខាន់នេះ ដែលធ្វើឱយខូចខាតដល់អត្ថបទគតិយុត្តិ ដែលជាមូលដ្ឋានរបស់ អ.វ.ត.ក" និង "*ហួសដែនសមត្ថកិច្ច* ដែលដូច្នេះហើយ ត្រូវចាត់ទុកជាមោឃៈ ដោយសារបង្កជាការព្យាយាមមួយធ្វើឱយខូចខាតគោលជំហរដើម ដែលមានចែងនៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក."[119]។

៣៦. ចៅក្រមអន្តរជាតិនៃ អ.ប.ជ. ក៏បានបញ្ជាក់បង្ហាញពីការខ្វែងយោបល់គ្នាជាមួយនឹង អ.ជ.ត.ក. ដែរ ទោះបដិសេធមិនពន្យល់ពីមូលហេតុដែល អ.ប.ជ. មិនបានអនុវត្តតាមឧបាស្រ័យ ដែល អ.ជ.ត.ក បានបញ្ជាក់ ដោយផ្អែកលើសេចក្តីប្រកាសផ្ទាល់របស់ អ.ប.ជ. ដោយយល់ឃើញថា អ.ជ.ត.ក.៖

ក. បានបង្កើត "ជំហានលោតផ្លោះមួយទៅដល់សំអាងហេតុ" ដោយ "ហាក់ដូចជានិយាយពាំត្រណោតចំពោះការសម្រេចរបស់ [អ.ប.ជ.] ដែលថា កម្រងសកម្មភាពរបស់ [ស.ច.ស.] ក្នុងការចេញដីកាដំណោះស្រាយ គឺខុសច្បាប់ ដោយមានការសន្និដ្ឋានថា ដីកាដំណោះស្រាយ គឺ "មោឃៈ" អញ្ចឹងឯង"[120]។

ខ. បានធ្វើ "សន្និដ្ឋានសរុបជារួម ដោយមិនមានការបង្ហាញដោយសមហេតុផល" ពីហេតុដែលអនីត្យានុកូលភាពផ្នែកនីតិវិធីនៃកិច្ចរបស់ ស.ច.ស. ក្នុងការបង្កើតដីកាដំណោះស្រាយ "នឹងបណ្តាលឱយមានការខូចខាតទាំងស្រុងទៅលើដីកាដំណោះស្រាយទាំងពីរ ដែលមានបញ្ហា" ពីព្រោះកំហុសឆ្គងនីតិវិធី ត្រូវតែបណ្តាលឱយមាន "លទ្ធផលមិនយុត្តិធម៌ទាំងស្រុងនៅក្នុងដំណើរការនីតិវិធីរបស់តុលាការ" ទើបនាំទៅរកការកែប្រែសាលក្រមនោះ[121]។

---

[119] *ដូចខាងលើ* កថាខណ្ឌ ២៦០, ២៦២។

[120] *ដូចខាងលើ* កថាខណ្ឌ ២៧៣។

[121] *ដូចខាងលើ* ជើងទំព័រ ៦០៩។

គ. "បានតាក់តែងឡើងយ៉ាងប៉ិនប្រសប់ ដើម្បីជាលេសដ៏ល្អ ក្នុងការនាំយកដំណើរការនីតិវិធីឈានទៅដល់ការបញ្ចប់ទៅ" "បុរេលក្ខខណ្ឌតម្រូវផ្នែករដ្ឋបាលអំពីការជូនដំណឹង និង ការបញ្ជូនដែលរងការចោទប្រកាន់"[122]។

ឃ. បានយល់ឃើញថា វាមិនចាំបាច់ទេ "ក្នុងការវិភាគលើអត្ថបទនៃសេចក្ដីសម្រេចជាក់ស្ដែងរបស់ [អ.ប.ជ.] ដើម្បីបញ្ជាក់បំភ្លឺ ... ថាតើ អ.ប.ជ. បានយល់ឃើញជាឯកច្ឆ័ន្ទដែរឬទេថាដីកាដំណោះស្រាយទាំងពីរ គឺ មោឃៈ និង ឥតបានការនោះ"[123]។

ង. បានបញ្ចប់តាមអំពើចិត្តនូវរឿងក្ដី 00៤/២ ដោយមិនមានដីកាដំណោះស្រាយ ដែល "មិននាំឱយមានភាពច្បាស់លាស់ ភាពស្ថាពរ និងសច្ចភាពខាងផ្លូវច្បាប់ឡើយ"[124]។

ច. បានធ្វើសេចក្ដីសម្រេចរបស់ខ្លួន ដោយមិនពិនិត្យមើលភស្តុតាងឡើងវិញ "តាមរយៈតែសេចក្ដីណែនាំបញ្ចប់ ដែលមានលក្ខណៈជាអនុក្រឹត្យទៅវិញ"[125]។

ឆ. បានបកស្រាយខុសលើសេចក្ដីសម្រេចជាឯកច្ឆ័ន្ទរបស់ អ.ប.ជ. លើដំណើរការត្រូវរ៉ូវគ្នាដោយខុសច្បាប់រវាង ស.ច.ស. "ក្នុងការគេចចេញពីនីតិវិធីដោះស្រាយការខ្វែងយោបល់" ដោយខកខានមិនបានអបអរសាទរថា ការស៊ើបអង្កេតត្រូវធ្វើបន្ត[126]។ និង

ជ. "បានពោលបញ្ឆិតបញ្ឆៀងថា បិទបញ្ចប់ដំណើរការនីតិវិធីគឺសមស្របហើយ ដោយសារការស៊ើបអង្កេតដែលមានរយៈពេលដប់បីឆ្នាំបានកន្លងផុតទៅហើយ ... [ដែល] មិនអាចប្រើប្រាស់ធ្វើជាមូលដ្ឋានគតិយុត្តិដែលសុពលឡើយ ដោយសារតែក្របខណ្ឌគតិយុត្តិ អ.វ.ត.ក. មិនចែងអំពីពេលវេលាកំណត់ជាក់លាក់ ដែល [អ.ជ.ត.ក.] អាចបិទបញ្ចប់សំណុំរឿងណាមួយ តាមរយៈដីកាសម្រេចបែបប្រតិបត្តិនោះ"[127]។

---

[122] *ដូចខាងលើ* ជើងទំព័រ ៥៩៤។

[123] *ដូចខាងលើ* កថាខណ្ឌ ២៧៤។

[124] *ដូចខាងលើ* កថាខណ្ឌ ២៧៩។

[125] *ដូចខាងលើ* កថាខណ្ឌ ២៨0។

[126] *ដូចខាងលើ* កថាខណ្ឌ ២៧៥។

[127] *ដូចខាងលើ* ជើងទំព័រ ៦២១។

៣៧. ***អ.ជ.ស.ជ. ជូនដំណឹងថាខ្លួនមិនបានទទួលរឿងក្តី ០០៣ មកពិនិត្យទេ។*** បន្ទាប់សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ ស.ព.អ. បានដាក់បញ្ជីឈ្មោះសាក្សីរបស់គាត់។ ក្រឡាបញ្ជីនៃ អ.ជ.ស.ជ. បានរំលឹកថា "អ.ជ.ស.ជ. មិនត្រូវបានជូនដំណឹងអំពី "សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនោះឡើយ" ហើយក៏មិនបានទទួលសំណុំរឿងនេះដែរ។ ដូច្នេះហើយ ទើប [អ.ជ.ស.ជ.] មិនទទួលយកសារទាក់ទងណាមួយពីភាគី (សូមមើលផងដែរ វិធាន ៧៧/១៤)"[128]។

៣៨. ***ស.ព.អ. ស្នើឱយ ស.ច.ស. បញ្ជូនសំណុំរឿង ០០៣ ទៅ អ.ជ.ស.ជ.។*** នៅថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០២១ ស.ព.អ. បានស្នើឱយ ស.ច.ស. ចាត់វាល់វិធានការរដ្ឋបាលចាំបាច់ទាំងអស់ ដើម្បីបង្គាប់ឱយផ្នែកគ្រប់គ្រងតុលាការបញ្ជូនរឿងក្តី ០០៣ ទៅ អ.ជ.ស.ជ.[129]។ មេធាវីការពារក្តីបានតបថា សំណើរបស់ ស.ព.អ. មិនអាចទទួលយកបានទេ ព្រោះដីកាដំណោះស្រាយទាំងពីរមោឃៈ និង ឥតបានការ ព្រោះចៅក្រមអន្តរជាតិនៃ អ.ប.ជ. មិនបានផ្តល់សំអាងហេតុ ឬ សំអាងផ្លូវច្បាប់សមស្របសម្រាប់ការងាកចេញពីការវិភាគរបស់ អ.ជ.ត.ក. ព្រោះ អ.ប.ជ. នៅតែមានរឿងក្តីនេះ នៅក្នុងដៃ ហើយ អ.ប.ជ. មិនបានសម្រេចដោយសំឡេងភាគច្រើនលើសលុបថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព[130]។

៣៩. ***ស.ច.ស. បដិសេធសំណើរបស់ ស.ព.អ. សុំឱយបញ្ជូនសំណុំរឿងនេះ។*** នៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២១ ស.ច.ស. បានច្រានសំណើរបស់ ស.ព.អ. ចោល ព្រោះថាមិនមានមូលដ្ឋានសមស្រប[131]។ ខណៈកាលបីមុន មានការជ្រើសយកការអត់ធ្មត់តាមផ្លូវតុលាការ "នៅឱកាសកើតផលពីសេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២" ស.ច.ស. ស្ថិតក្នុងករណីបន្ទាន់បង្ខំ បាន

---

[128] សារអេឡិចត្រូនិករបស់លោកស្រី លឹម ស៊ុយហុង ចំណងជើងថា "កម្មវត្ថុ៖ សំណើសុំបន្ថែមពេលវេលាដើម្បីដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញស្របតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០២១។

[129] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅកាន់សហចៅក្រមស៊ើបអង្កេតសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០២១ ឯកសារ D270។

[130] ចម្លើយរបស់ មាស មុត តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅកាន់សហចៅក្រមស៊ើបអង្កេតសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០២១ ឯកសារ D270/4 កថាខណ្ឌ ១៨។

[131] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០២១ ឯកសារ D270/7 ("សេចក្តីសម្រេចរបស់ ស.ច.ស. ស្តីពីការបញ្ជូនសំណុំរឿង ០០៣") កថាខណ្ឌ ២៨។

ដឹងថា មានភាពចាំបាច់ដែលត្រូវរម្លឹកដល់សមភាគីរបស់ពួកគេនៅក្នុង អ.ប.ជ. អំពីភារកិច្ចរបស់ខ្លួន តាមក្រមអភិសមាចារតុលាការជាតិរៀងៗខ្លួន និង អំពីច្បាប់ទូទៅស្តីពីការបរិហារ និង បង្កាច់កេរ្តិ៍ ក្នុងការចោទប្រកាន់ ស.ច.ស. ថាបានបង្វែរដំណើរការយុត្តិធម៌នោះ តាមរយៈការគេចវេសដោយចេតនាពីយន្តការដោះស្រាយវិវាទ[132]។ កាលនោះ ស.ច.ស. បានពន្យល់លម្អិតពីព្រឹត្តិការណ៍ដែលនាំទៅការចេញដីកាដំណោះស្រាយដាច់ដោយឡែកនិងផ្ទុយគ្នា ការយល់ឃើញរបស់ពួកគាត់អំពីភាពត្រឹមត្រូវ និង ផលប៉ះពាល់នៃសេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ ហើយ និង ការយល់ឃើញរបស់ពួកគាត់អំពីឧបាស្រ័យដែលមានចំពោះ អ.ប.ជ. ក្នុងការដោះស្រាយភាពទាល់ច្រកផ្នែកនីតិវិធីបច្ចុប្បន្ន[133]។

៤០. ស.ច.ស. បានយល់ឃើញថា "មិនមានចំណុចណាមួយ ទោះអ្វីក៏ដោយ ក្នុងការបង្កឱយមាននីតិវិធីខ្វែងយោបល់គ្នាលើយុត្តាធិការនៅចំពោះមុខ អ.ប.ជ. ឡើយ ព្រោះលទ្ធផលគឺជាការសន្និដ្ឋាន ដែលចៀសមិនរួចនោះឡើយ"[134]។ "ការធ្វើដូច្នេះគឺមានន័យថា ជាការពន្យារពេលដែលមិនចាំបាច់ និង ការចំណាយពេលវេលា និង ធនធានដោយឥតប្រយោជន៍"[135] ព្រោះ "បើទោះបីជាពួកយើងស្នើសុំដល់ អ.ប.ជ. ឱយចេញសេចក្តីសម្រេចលើបញ្ហាភាពស្របច្បាប់នៃដីកាដំណោះស្រាយដាច់ពីគ្នាក្តី ក៏ប្រហែលជាពួកយើងទទួលបានព័ត៌មានមកវិញថា នេះមិនមែនជានីតិវិធីនៃការខ្វែងយោបល់គ្នានោះទេ តែជាសំណើសុំមតិប្រឹក្សាជាអ្វីដែល អ.ប.ជ. ... បដិសេធជារៀងរហូតមិនធ្វើការពិចារណា"[136]។

៤១. ស.ច.ស. ក៏បានកត់សម្គាល់ផងដែរថា អ.ប.ជ. កាលពីដើមខែសីហា ឆ្នាំ ២០១៤ ត្រូវបានស្នើសុំឱយផ្តល់ការយល់ឃើញផ្ទាល់ខ្លួនលើបញ្ហាច្បាប់នេះ ក្នុងករណី ស.ច.ស. ចេញដីកាដំណោះស្រាយដាច់ពីគ្នានិងផ្ទុយគ្នា ដោយផ្អែកលើការខ្វែងយោបល់រវាង ស.ច.ស.[137]។ អ.ប.ជ. បានយល់ឃើញ

---

[132] *ដូចខាងលើ* កថាខណ្ឌ ៩-១៥។

[133] *ដូចខាងលើ* កថាខណ្ឌ ១៥-២៥។

[134] *ដូចខាងលើ* កថាខណ្ឌ ១៥។

[135] *ដូចខាងលើ* កថាខណ្ឌ ១៥។

[136] *ដូចខាងលើ* កថាខណ្ឌ ២០ ដោយដកស្រង់ *រឿងក្តី យឹម ទិត្យ* សំណុំរឿងលេខ ០០៤/០៤-០៩-២០០៩-អ.វ.ត.ក/ ក.ស.ច.ស (អ.ប.ជ១១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D205/1/1/2 កថាខណ្ឌ ៧-៨។

[137] សេចក្តីសម្រេចរបស់ ស.ច.ស. ស្តីពីការបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ២០។

ថា "គម្រូមធ្យោបាយ (សេណារីអូ) ដែលប្រមើលមើលនៅក្នុងសំណើនោះ ... គឺជាសម្មតិកម្ម" គឺសន្មត ហើយ អញ្ចឹងឯង ទើប អ.ប.ជ. បានសម្រេចថា ខ្លួន "ពុំមានយុត្តាធិការវែកញែកបញ្ហាដែលជាសម្មតិកម្ម ឬ ផ្តល់នូវមតិយោបល់ណែនាំនោះទេ"[138]។

៤២. ស.ច.ស. "ដូចគ្នានឹង អ.ជ.ត.ក. ណាស់ បានវង្វេងវង្វាន់លែងដឹងថា ចៅក្រមនៃ អ.ប.ជ. អាចលើកឡើង*រួមគ្នា* របៀបណានៅក្នុងរឿងក្តី ០០៤/២ ដែលថាដីកាដំណោះស្រាយដាច់ពីគ្នា គឺខុសច្បាប់យ៉ាងច្បាស់ក្រឡែត និង ជាការរំលោភបំពានទៅលើក្របខណ្ឌរបស់ អ.វ.ត.ក. ដោយចៅក្រមជាតិ និង ចៅក្រមអន្តរជាតិ បន្តពិភាក្សាលើអង្គសេចក្តីនៃដីកាដំណោះស្រាយនីមួយៗ ហើយឈានទៅដល់ការយល់ផ្សេងគ្នា ក្នុងការសម្រេចតម្កល់ដីកាដំណោះស្រាយ ដែលត្រូវបានប្តឹងឧទ្ធរណ៍ទៅកាន់ពួកគេនោះ"[139]។

៤៣. ស.ច.ស. បានពិចារណាថា "ប្រសិនបើកំហុសរបស់ពួកខ្លួន ក្នុងការចេញដីកាដំណោះស្រាយដាច់ពីគ្នា អាក្រក់បំផុតដូចបានរៀបរាប់យ៉ាងវែងដោយ អ.ប.ជ. នៅក្នុងសេចក្តីពិចារណាទាំងពីរនោះ ជាការដ៏ត្រឹមត្រូវបំផុត ដែលដីកាដំណោះស្រាយ*ទាំងពីរ* គួរតែត្រូវបានបដិសេធចោលភ្លាមៗ និង ជាឯកច្ឆ័ន្ទ ដោយសារតែវិការៈនីតិវិធីដ៏ធ្ងន់ធ្ងរ ដោយ អ.ប.ជ. មិនចាំបាច់ចំណាយពេលវេលាលើការពិភាក្សាអំពីអង្គសេចក្តីឡើយ ហើយសំណុំរឿងត្រូវបង្វិលត្រឡប់មកពួកខ្លួន ដោយមានសេចក្តីណែនាំមិនឱយមានដីកាដំណោះស្រាយដាច់ពីគ្នា"[140]។ "កំហុសនីតិវិធីនៃដីកាដែលមានស្ថានទម្ងន់បែបនេះនៅក្នុងសេចក្តីសម្រេចណាមួយ នៅអំឡុងកាលស៊ើបអង្កេត ប្រាកដណាស់នឹងនាំទៅដល់មោឃកម្មដីកានោះ ហើយចាំបាច់ត្រូវលុបចេញពីសំណុំរឿងដោយសារតែអសារឥតការ"[141]។

៤៤. ពាក់ព័ន្ធនឹងអនុភាពផ្លូវច្បាប់នៃសេចក្តីពិចារណារបស់ អ.ប.ជ. ស.ច.ស. បានយល់ឃើញថា "មានតែផ្នែករួមគ្នានៃសេចក្តីពិចារណារបស់ អ.ប.ជ. ប៉ុណ្ណោះ ដែលអាចមានអនុភាពចងកាតព្វកិច្ច ព្រោះផ្នែកនេះត្រូវបានព្រាងជាឯកច្ឆ័ន្ទ"[142]។ "ការទទូចទាមទាររបស់ចៅក្រមអន្តរជាតិ នៅក្នុងរឿងក្តី ០០៤/២ និង រឿងក្តី ០០៣ ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ហើយដីកា

---

[138] *ដូចខាងលើ* កថាខណ្ឌ ២០។

[139] *ដូចខាងលើ* កថាខណ្ឌ ២១។

[140] *ដូចខាងលើ* កថាខណ្ឌ ២១។

[141] *ដូចខាងលើ* កថាខណ្ឌ ២១។

[142] *ដូចខាងលើ* កថាខណ្ឌ ២៣។

សម្រេចលើកលែងចោទប្រកាន់ គឺ *ហួសពីសិទ្ធិអំណាច* ឬ "អនុលោមតិចតួច"នឹងច្បាប់ជាធរមាន គឺគ្រាន់តែដោយសារលទ្ធផលនោះ ស្របទៅតាមវិធានរកសំឡេងមិនបាន គឺពិតជាមិនគួរឱយជឿបានឡើយ ដោយសារចៅក្រមជាតិ បើទោះបីជាអនុវត្តផ្ទុយទៅនឹងអ្វីដែលពួកគេបានសម្រេចរួមគ្នាជាមួយចៅក្រមអន្តរជាតិក្តី តែបែរជាជ្រើសរើសយកការធ្វើដំណើរក្នុងទិសដៅផ្ទុយទៅវិញ"[143]។ ក្រៅពីនេះ ស.ច.ស. ក៏បានយល់ឃើញថា ចៅក្រមជាតិនៃ អ.ប.ជ. "ធ្វើការបត់ត្រឡប់ក្រោយជាភាសាហៅថា U-turn" ដោយលើកឡើង "ក្នុងសំណុំរឿង ០០៣ ថា *ដីកាដំណោះស្រាយទាំងពីរមានសុពលភាពនោះ* គឺមិនអាចផ្លាស់ប្តូរសេចក្តីសន្និដ្ឋាននោះឡើយ ព្រោះពួកគេនៅតែបន្ត ហើយផ្តល់ដោយផ្ទាល់នូវសេចក្តីណែនាំ*រដ្ឋបាល* ថា សំណុំរឿង ០០៣ ត្រូវរក្សាទុកក្នុងបណ្ណសារ"[144]។

៤៥. ស.ច.ស. បានផ្តល់ដំណោះស្រាយចំនួនបី ដើម្បីបំបែកភាពទាល់ច្រកក្នុងរឿងក្តី ០០៣ ដោយកត់សម្គាល់ថា អ.ប.ជ. មានឱកាសអនុវត្តដំណោះស្រាយទាំងនោះ៖ (ក) "ឬ ជាឯកច្ឆ័ន្ទបង្វិលត្រឡប់សំណុំរឿងមកពួកខ្លួនវិញ ដោយសារតែកំហុសនីតិវិធីធ្ងន់ធ្ងរ ហើយមិនចាំបាច់ពាក់ព័ន្ធជាមួយអង្គសេចក្តី ដោយមានសេចក្តីណែនាំឱយចេញដីកាដំណោះស្រាយតែមួយរួមគ្នា" (ខ) "ឬក៏បំពេញកិច្ចការដោយខ្លួនឯងផ្ទាល់ជាឯកច្ឆ័ន្ទ ដោយអនុវត្តវិធានរកសំឡេងមិនបាន ហើយបញ្ជូនសំណុំរឿងទៅជំនុំជម្រះ" (គ) ឬមួយ "ដោយសារការខ្វែងយោបល់គ្នា នៅមានជាក់ស្តែងនឹង អ.ប.ជ. ... ធ្វើការបិទបញ្ចប់សំណុំរឿង ដូចដែល អ.ជ.ត.ក. បានសម្រេចជាស្ថាពរក្នុងសំណុំរឿង ០០៤/២"[145]។

## II. ភាពអាចទទួលយកបាន

៤៦. អ.ប.ជ. មានភារកិច្ចតាមផ្លូវតុលាការ ក្នុងការប្រកាសលើបញ្ហាទាំងឡាយ ដែលលើកឡើងក្នុងសំណើនេះ ជា "យុត្តាធិការចុងក្រោយបង្អស់លើដំណាក់កាលបុរេជំនុំជម្រះ"[146]។ ភារកិច្ចតាមផ្លូវតុលាការក្នុងការប្រកាស ដោយផ្អែកទៅលើច្បាប់ ពីសេចក្តីសម្រេចលើបញ្ហាវិវាទ ... *គឺជាចំណុចសំខាន់បំផុតនៃការទទួលខុសត្រូវ និង មុខងារដ៏ខ្ពង់ខ្ពស់បំផុតរបស់ចៅក្រម*"[147]។ ហេតុដូច្នេះ ការ "ប្រកាសសម្រេចវិនិច្ឆ័យ និង ការដោះស្រាយបញ្ហាដែលជាជម្លោះ ត្រូវមានឥទ្ធិពល និង ជាកាតព្វ

---

[143] សេចក្តីសម្រេចរបស់ ស.ច.ស. ស្តីពីការបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ២៣។

[144] *ដូចខាងលើ* កថាខណ្ឌ ២៤។

[145] *ដូចខាងលើ* កថាខណ្ឌ ២៥។

[146] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៤១, ១២២។

[147] *ដូចខាងលើ* កថាខណ្ឌ ១២២ (ការគូសបញ្ជាក់បន្ថែម)។

កិច្ចផ្លូវច្បាប់” ដូច្នេះ អ.ប.ជ. “មិនអាចគេចចេញពីការវិនិច្ឆ័យលើបញ្ហាដែលនៅចំពោះមុខ[ខ្លួន] ឡើយ” សូម្បីតែក្នុងករណីដែលច្បាប់នោះ “មិនមានចែង ចែងមិនច្បាស់ ឬ មិនគ្រប់គ្រាន់”[148]។ អ.ប.ជ. មានការ “ប្តេជ្ញាចំពោះសច្ចភាពផ្លូវច្បាប់ និង ដំណើរការនីតិវិធីប្រកបដោយតម្លាភាព” ក្រោមវិធាន ២១[149] គឺថា ត្រូវបកស្រាយក្របខណ្ឌ អ.វ.ត.ក. “ក្នុងន័យការពារជានិច្ចដល់ប្រយោជន៍” របស់ជនត្រូវចោទ[150]។ ក្រៅពីនេះ អ.ប.ជ. ក៏មានសិទ្ធិអំណាចដែលជាប់ជាមួយ “ដើម្បីកំណត់ពីបញ្ហាបន្ទាប់បន្សំនានា ដែលកើតឡើងដោយសារតែផលវិបាកផ្ទាល់នៃនីតិវិធីដែលត្រូវបានប្តឹងមកខ្លួន ដោយផ្តល់សំអាងហេតុថា បញ្ហានោះស្ថិតនៅក្រោមយុត្តាធិការបឋមរបស់ខ្លួន”[151] និង មានកាតព្វកិច្ចអនុវត្តសិទ្ធិអំណាច ក្នុងករណីនេះ “ដោយសារតែតម្រូវការចាំបាច់ក្នុងការធានាឱយបាននូវកិច្ចការរដ្ឋបាលតុលាការដែលល្អ និង មានយុត្តិធម៌”[152]។ ចុងបញ្ចប់ សំណើនេះពាក់ព័ន្ធនឹង “បញ្ហាធំធេងនានាជាទូទៅសម្រាប់យុត្តិសាស្ត្រ និង កេរដំណែលរបស់ អ.វ.ត.ក.”[153] នោះ គឺការសម្រេចមួយដែលនឹងបញ្ជាក់បំភ្លឺពីនីតិវិធីនេះជាថ្មីម្តងទៀត និង ជារួម និង សម្រាប់រឿងក្តីចុងក្រោយរបស់ អ.វ.ត.ក. នៅក្នុងដំណាក់កាលស៊ើបអង្កេត តាមរយៈនោះ នឹងជួយសន្សំសំចៃពេលវេលា ធនធានតុលាការ និង មូនិធិរបស់ម្ចាស់ជំនួយ។

## III. ច្បាប់ និងឧត្តរីករណ៍

៤៧. ដំណើរការនីតិវិធីមុនជំនុំជម្រះ ប្រឆាំងនឹង លោក មាស មុត រយៈពេល ១៣ ឆ្នាំ ទោះតាមការគិតស្រមៃ មិនសមស្របនឹងសិទ្ធិរបស់គាត់ ក្នុងការទទួលបានដំណើរការនីតិវិធីឆាប់រហ័ស ដូចមាន

[148] *ដូចខាងលើ* កថាខណ្ឌ ១២២។ ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៤ “ចៅក្រមដែលបដិសេធមិនចេញសាលក្រមដោយលេសថាច្បាប់មិនមានចែង ចែងមិនច្បាស់ ឬមិនគ្រប់គ្រាន់ អាចត្រូវបានផ្តន្ទាទោសពីពិរុទ្ធភាពនៃការបដិសេធមិន ផ្តល់យុត្តិធម៌” [ការបកប្រែ Legifrance]។

[149] សេចក្តីពិចារណារបស់ អ.ប.ជ ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦៨។

[150] *ដូចខាងលើ* កថាខណ្ឌ ៥១។

[151] *ដូចខាងលើ*។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើសុំអង្គបុរេជំនុំជម្រះបកស្រាយទូលាយអំពីវិសាលភាពដែលអាចអនុញ្ញាតបាននៃបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ និង បញ្ជាក់បំភ្លឺអំពីនីតិវិធីមោឃភាពដីកាដំណោះស្រាយ ឬ ផ្នែកនានានៃដីកាដំណោះស្រាយ ប្រសិនបើចាំបាច់ ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D158/1 កថាខណ្ឌ ១១។ *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/-១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(២៦) សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៣ ឯកសារ E284/2/1/2 កថាខណ្ឌ ១២។

[152] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៥១។

[153] *ដូចខាងលើ* កថាខណ្ឌ ៣២, ៥០។

ចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ក្នុងក្របខណ្ឌ អ.វ.ត.ក. និង ក្នុងអនុសញ្ញាសិទ្ធិមនុស្សនៅជុំវិញពិភពលោកឡើយ។ សូម្បីយ៉ាងនោះក្តី ដំណើរផ្សងព្រេងនេះនៅតែបន្ត រឿងក្តី ០០៣ ដែលកំពុងស្ថិតក្នុងដៃរបស់ អ.ប.ជ. កំពុងកប់ជ្រៅក្នុងដំណើរការតុលាការ។ ដូចគ្នានឹងជនត្រូវចោទក្នុងរឿងក្តី ០០៤/២ ដែរ ភាគីជាតិ និង ភាគីអន្តរជាតិនៃ អ.ប.ជ. មិនព្រមព្រៀងគ្នាអំពីថាតើ លោក មាស មុត ត្រូវតាមលក្ខខណ្ឌផ្នែកយុត្តាធិការ ដែលត្រូវជំនុំជម្រះដោយ អ.វ.ត.ក. ឬយ៉ាងណា។ ដូចដំណើរវដ្តៈនៃទិវានិងរាត្រី មានការខ្វែងយោបល់គ្នាកាន់តែវែងឆ្ងាយ ភាពជាប់គាំងចេះតែបន្តទៀត ហើយការពន្យារពេលបន្ថែមលាតសន្ធឹង ចៀសមិនផុត ដែលនាំឱយមានការរំលោភនីតិវិធី និង ការរំលោភជាបន្តបន្ទាប់លើសិទ្ធិដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ អ.ប.ជ. មិនអាចបោះបង់ការទទួលខុសត្រូវរបស់ខ្លួនចោលឡើយ។ ការដោលបញ្ហានេះទៅអង្គជំនុំជម្រះផ្សេងទៀតឱយកាត់ចំណងដ៏ស្មុគស្មាញនេះ និង ដោះស្រាយភាពទាល់ច្រកក្នុងរឿងក្តី ០០៣ ដែល អ.ប.ជ. មិនអាចគេចវេសពីការទទួលខុសត្រូវរបស់ខ្លួន មិនមែនជាជម្រើសដែលអាចសម្រេចកើតនោះទេ។ ប្រសិនបើ អ.ប.ជ. គ្មានលទ្ធភាពសម្រេចបានសំឡេងភាគច្រើនលើសលុបក្នុងការបញ្ជូន លោក មាស មុត ទៅជំនុំជម្រះទេ នោះ អ.ប.ជ. ត្រូវបញ្ចប់រឿងក្តី ០០៣ បោះត្រា និង ដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារ។ ទោះតាមវិធីណាមួយក៏ដោយ អ.ប.ជ. *ត្រូវ* បំពេញកិច្ចនេះយ៉ាងប្រាកដប្រជា និង ឱយបានឆាប់រហ័ស។ លោក មាស មុត មានសិទ្ធិ។

### ក. លោក មាស មុត មានសិទ្ធិទទួលបានដំណើរការនីតិវិធីឆាប់រហ័ស

៤៨. វិធាន ២១(៤) តម្រូវថា ដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក. "ត្រូវបញ្ចប់ក្នុងរយៈពេលមួយសមស្រប"[154]។ សិទ្ធិទទួលបានដំណើរការនីតិវិធីឆាប់រហ័សក្នុងវិធាន ២១(៤) គូគ្នានឹងមាត្រា ៣៥ *ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. គឺជាគោលការណ៍មូលដ្ឋានដែលមានចែងក្នុងមាត្រា ១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("កតិកាសញ្ញា ICCPR")[155] ត្រូវ

---

[154] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧/-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 ("សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/១") កថាខណ្ឌ ២៨។ សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦១។ សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១៣៥។

[155] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/១ កថាខណ្ឌ ២៨។ សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦១។ សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១៣៥។

បានដាក់បញ្ចូលក្នុងមាត្រា ៣១ និង មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា[156] ហើយក៏ត្រូវបានឆ្លុះបញ្ចាំងក្នុងអនុសញ្ញាស្តីពីសិទ្ធិមនុស្សរបស់អឺរ៉ុប អាហ្វ្រិក និង អាមេរិកផងដែរ[157]។

៤៩. សិទ្ធិទទួលបានដំណើរការនីតិវិធីឆាប់រហ័ស "ត្រូវបានរៀបចំឡើង ដើម្បីរារាំងកុំឱយនរណាម្នាក់ស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជាអំពីជោគវាសនារបស់ខ្លួនយូរខ្លាំងពេក"[158] និង "អនុវត្តនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីទាំងអស់នៅចំពោះមុខ អ.វ.ត.ក. រួមទាំងដំណាក់កាលមុនការជំនុំជម្រះដែរ"[159]។ "ចំណុចចាប់ផ្តើមសម្រាប់ការវាយតម្លៃលើរយៈពេលសមហេតុផលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ គឺនៅពេលជនសង្ស័យត្រូវបានជូនដំណឹងជាផ្លូវការថា ខ្លួននឹងត្រូវរងការចោទ

---

[156] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា ត្រូវគោរពសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដូចមានចែង *ក្នុងចំណោមនោះ* ក្នុងកតិកាសញ្ញា ICCPR។ កិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ក៏តម្រូវឱ្យមានការគោរពសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ដូចមានចែងក្នុងកតិកាសញ្ញា ICCPR ផងដែរ។ *សូមមើល* មាត្រា ១២ (២), មាត្រា ១៣ (១) នៃកិច្ចព្រមព្រៀង។ មាត្រា ៣៣ ថ្មី មាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ២០០៤) ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.")។

[157] មាត្រា ៦ (១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិ និង សេរីភាពជាសារវ័ន្តរបស់មនុស្ស និងប្រជាជន ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៥០ 213 U.N.T.S. 221។ មាត្រា ៧ (១) នៃធម្មនុញ្ញអាហ្វ្រិក (Banjul) ស្តីពីសិទ្ធមនុស្ស និងសិទ្ធិប្រជាជន ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ១៩៨១ 1520 U.N.T.S. 217។ មាត្រា ៧ (៥) នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស 1144 U.N.T.S. 123 ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ១៩៧៨។

[158] គណៈកម្មាធិការសិទ្ធិមនុស្ស មតិយោបល់រួមលេខ ៣២ មាត្រា ១៤៖ សិទ្ធិទទួលបានសមភាពនៅចំពោះមុខតុលាការ និងសាលាក្តី និង សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ CCPR/C/GC/32 ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ ៣៥។

[159] *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាសម្រេចចេញសាឡើងវិញលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D120/3/1/8 មតិយោបល់ចៅក្រម Beauvallet និងចៅក្រម Baik ("សេចក្តីពិចារណារបស់ អ.ប.ជ. អន្តរជាតិលើញត្តិសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម") កថាខណ្ឌ ៣៥ ដោយដកស្រង់ *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ៤២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំឮ្យកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ១៣។ *សូមមើលផងដែរ* គណៈកម្មាធិការសិទ្ធិមនុស្ស មតិយោបល់រួមលេខ ៣២ មាត្រា ១៤៖ សិទ្ធិទទួលបានសមភាពនៅចំពោះមុខតុលាការ និងសាលាក្តី និង សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ CCRP/C/GC/32 ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០០៧ កថាខណ្ឌ ៣៥ ("មតិយោបល់រួមលេខ ៣២")៖ "នៅគ្រប់ដំណាក់កាលទាំងអស់ មិនថានៅសាលាដំបូង ឬ ក្នុងដំណាក់កាលប្តឹងឧទ្ធរណ៍នោះទេ ត្រូវធ្វើឡើង "ដោយមិនពន្យារពេល"។

ប្រកាន់ បើទោះជាជនសង្ស័យមិនត្រូវបានចោទប្រកាន់ជាផ្លូវការរហូតដល់ដំណាក់កាលក្រោយមកក៏ដោយ”[160]។

៥០. ការវាយតម្លៃលើភាពឆាប់រហ័សនៃដំណើរការនីតិវិធីត្រូវធ្វើឡើង “ដោយពិនិត្យមើលកាលៈទេសៈ” ដោយពិចារណាលើការ “ប្រព្រឹត្តរបស់អាជ្ញាធរមានសមត្ថកិច្ច” ភាពស្មុគស្មាញនៃរឿងក្តី ហើយនឹងចរិយារបស់ជនត្រូវចោទ[161]។ “កត្តានានាប្រាប់ឱយដឹងពីភាពលឿនឆាប់រហ័ស” រួមមាន “វ័យ និងសុខភាពរបស់ជនត្រូវចោទ អនុភាពនៃការពន្យារពេលទៅលើភស្តុតាង និង សក្ខីកម្មរបស់សាក្សី ហើយនិងរយៈពេលនៃការស៊ើបអង្កេតទាំងមូល”[162]។

## ខ. ការពន្យារពេលយូររហូតដល់ ១៣ ឆ្នាំ លើដំណើរការនីតិវិធីនៅមុនពេលជំនុំជម្រះរឿងក្តី ០០៣ គឺមិនសមហេតុផលទេ

៥១. “យ៉ាងជាក់ស្តែង ការពន្យារពេលហួសហេតុ និងអាចចៀសវាងបាន”[163] រយៈពេល ១៣ ឆ្នាំ លើដំណើរការនីតិវិធីមុនជំនុំជម្រះរឿងក្តី ០០៣ បណ្តាលមកពីរបៀប ដែល“អាជ្ញាធរមានសមត្ថកិច្ច”[164] ពោលគឺ សមាសភាពជាតិ និង អន្តរជាតិនៃ អ.វ.ត.ក. បានវែកញែកពីការមិនចុះសម្រុងគ្នាថាតើគួរបញ្ជូន លោក មាស មុត ទៅជំនុំជម្រះឬអត់[165]៖

ក. ការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា តាំងពីចាប់ផ្តើមការស៊ើបអង្កេត ក្នុងរឿងក្តី ០០៣ ធ្វើឱយមានការពន្យារពេលអស់រយៈមួយឆ្នាំ ក្នុងការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱយស៊ើបសួរ ចាប់តាំងពីការទទួលបានចម្លើយដ៏សោះកក្រោះរបស់ អ.ប.ជ. មានការដាក់

---

[160] សេចក្តីពិចារណារបស់ អ.ប.ជ. អន្តរជាតិលើញត្តិសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ ៣៥ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[161] សេចក្តីពិចារណារបស់ អ.ប.ជ. អន្តរជាតិលើញត្តិសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ ៣៧ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[162] សេចក្តីពិចារណារបស់ អ.ប.ជ. អន្តរជាតិលើញត្តិសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ ៣៥ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[163] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ១៤៩។

[164] *សូមមើល* សេចក្តីពិចារណារបស់ អ.ប.ជ. អន្តរជាតិលើញត្តិសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ ៣៧ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[165] *សូមមើល* សេចក្តីពិចារណារបស់ អ.ប.ជ. អន្តរជាតិលើញត្តិសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ ៣៧។

សំណើបន្ថែមទៀតដោយសហព្រះរាជអាជ្ញា និង ការស្នើសុំសំណើជាក់លាក់បន្ថែមទៀតពី អ.ប.ជ.[166]។

ខ. ស.ច.ស. ដែលមាន ស.ច.ស.ជ. ម្នាក់ និង ស.ច.ស.អ. ៥ នាក់ បានស៊ើបអង្កេតរយៈពេល ១១ ឆ្នាំ ដោយមានការពន្យារពេលម្តងម្កាល រហូតដល់មានការខ្វែងយោបល់គ្នា ទៅលើថាតើ អ.វ.ត.ក. មានយុត្តាធិការបុគ្គលទៅលើលោក មាស មុត និង ការចេញដីកាដំណោះស្រាយដាច់ពីគ្នា និងផ្ទុយគ្នា ឬទេ[167]។

គ. យ៉ាងហោចណាស់ក៏បីដងដែរ នៅមុនការបញ្ចប់ការស៊ើបអង្កេត និង ការចេញដីកាដំណោះស្រាយ ចៅក្រមជាតិនៃ អ.ប.ជ. បានបង្ហាញការយល់ឃើញរបស់ខ្លួនថា ពួកគាត់មិនយល់ស្របឡើយថា អ.វ.ត.ក. មានយុត្តាធិការបុគ្គលលើលោក មាស មុតទេ[168] ដោយលើកឡើងដដែលៗ ពីការយល់ស្របរបស់ខ្លួនទៅនឹង ស.ព.ជ. តាំងពីពេលចាប់ផ្តើមរឿងក្តី ០០៣ ថា

---

[166] *សូមមើល ខាងលើ* កថាខណ្ឌ ២-៣។ ឧបសម្ព័ន្ធ ១ ៖ សំណៅសាធារណៈមានកោសលុប សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោលបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៩ ឯកសារ D1/1.3 កថាខណ្ឌ ១-៩, ៤៥។

[167] *សូមមើល ខាងលើ* កថាខណ្ឌ ៤-១១។

[168] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាសម្រេចចេញសាឡើងវិញលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D120/3/1/8 មតិយោបល់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ២៧។ សាលដីការបស់អង្គបុរេជំនុំជម្រះ ១) លើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណើសុំចំនួនប្រាំបួនរបស់ មាស មុត សុំប្តឹងទៅអង្គបុរេជំនុំជម្រះឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង ២) លើសំណើសុំចំនួនពីរដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១៦ ឯកសារ D165/2/26 មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ពាក់ព័ន្ធនឹងសំណើទាំងប្រាំបួនរបស់ មាស មុត សុំមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ ៩៦។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៧ ឯកសារ D87/2/1.7/1/1/7 មតិយោបល់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ កថាខណ្ឌ ៧២។

មិនគួរចោទប្រកាន់ ឬ ស៊ើបអង្កេតសំណុំរឿងនេះឡើយ ព្រោះ "ជនសង្ស័យទាំងនោះមិនមែនជាមេដឹកនាំកំពូល និង/ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុត"នោះទេ[169]។

ឃ. អ.ប.ជ. ចំណាយពេល ១៦ ខែ បន្ទាប់ពីទឡ្ហីករណ៍ផ្ទាល់មាត់លើដីកាដំណោះស្រាយទាំងនេះក្នុងរឿងក្តី ០០៣ ដើម្បីប្រកាសថា ការចេញដីកាដំណោះស្រាយពីរគឺខុសច្បាប់ (បន្ទាប់ពីបានប្រកាសដូច្នេះក្នុងរឿងក្តី ០០៤/២) មិនអនុវត្តឧបាស្រ័យណាមួយ ដែលកំណត់ដោយ អ.ជ.ត.ក. (ដែលត្រូវបានពឹងផ្អែកលើការប្រកាសផ្ទាល់របស់ អ.ប.ជ.) និង ជាថ្មីម្តងទៀតបង្ហាញពីទស្សនៈផ្ទុយគ្នាដាច់ពីគ្នា ចំពោះរឿងក្តី០០៣ ដែលត្រូវដាក់បញ្ចូលទៅក្នុងបណ្ណសារ និង បញ្ជូនទៅជំនុំជម្រះ[170]។ និង

ង. ស.ច.ស. នៅពេលត្រូវបានស្នើឱយបញ្ជូនសំណុំរឿងនេះ បន្ទាប់ពីការពិចារណារបស់ អ.ប.ជ ក៏បានកំណត់ថា ពួកគេមិនបានទទួលប្តឹងឱយពិនិត្យលើបញ្ហានេះ ដូច្នេះ មិនអាចបំពេញកិច្ចបានទេ[171]។

៥២. ភាពស្មុគស្មាញ ទាំងមិនពន្យល់ ឬ ទាំងមិនដោះសារពីដំណើរការនីតិវិធីមុនជំនុំជម្រះរយៈពេល ១៣ ឆ្នាំ ក្នុងរឿងក្តី ០០៣ ឡើយ[172]។ ដំណើរការនីតិវិធីមុនជំនុំជម្រះក្នុងរឿងក្តី ០០៣ មានរយៈពេលលើសពីបីដង យូរជាងដំណើរការនីតិវិធីមុនជំនុំជម្រះក្នុងរឿងក្តី ០០២ ដែលពាក់ព័ន្ធនឹងជនត្រូវចោទបួននាក់ ទាក់ទិននឹងទីតាំងឧក្រិដ្ឋកម្ម និង ព្រឹត្តិការណ៍ចំនួន ២៤ បន្ថែមពីលើប្រវត្តិរបស់បក្សកុម្មុយនីស្តកម្ពុជា រចនាសម្ព័ន្ធរដ្ឋបាល រចនាសម្ព័ន្ធយោធា និង គោលនយោបាយ[173]។ ផ្ទុយទៅវិញ

[169] មតិយោបល់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ពាក់ព័ន្ធនឹងសំណើទាំងប្រាំបួនរបស់ មាស មុត សុំមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ ៩៦។ មតិយោបល់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ កថាខណ្ឌ ៧២។

[170] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ ទំព័រ ៥៦។ *សូមមើល ខាងលើ* កថាខណ្ឌ ២៧-៣៧។

[171] *សូមមើល ខាងលើ* កថាខណ្ឌ ៣៩-៤៥។

[172] *សូមមើល* សេចក្តីពិចារណារបស់ អ.ប.ជ. អន្តរជាតិលើញត្តិសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ ៣៧។

[173] *សូមមើល រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D427។

រឿងក្តី ០០៣ ពាក់ព័ន្ធនឹងជនត្រូវចោទម្នាក់ ដែលទាក់ទិននឹងទីតាំងឧក្រិដ្ឋកម្ម និង ព្រឹត្តិការណ៍ចំនួនប្រាំបី និង តួនាទីកងទ័ពបដិវត្តន៍កម្ពុជារបស់គាត់[174]។

៥៣. ទង្វើរបស់លោក មាស មុត មិនបណ្តាលឱយមានការពន្យារពេលដំណើរការនីតិវិធីឡើយ[175]។ គាត់បានអនុវត្តតាមលក្ខខណ្ឌដែលបង្គាប់ដោយ ស.ច.ស.អ. Bohlander[176] និង មិនប្រើកលយុទ្ធពន្យារពេលនោះទេ។ ហើយទោះបីជាការយល់ឃើញរបស់ចៅក្រមអន្តរជាតិនៃ អ.ប.ជ. ផ្ទុយពីនេះក្តី ក៏ការចោទប្រកាន់ផ្ទាល់របស់ ស.ច.ស.អ. Bohlander លើលោក មាស មុត នៅខេត្តបាត់ដំបង ក្នុងឆ្នាំ ២០១៥ មិនបានធ្វើឱយមានការពន្យារពេលនោះទេ[177]។

៥៤. លោក មាស មុត មានអាយុ ៨២ ឆ្នាំ[178]។ ក្នុងរយៈពេល ១៣ ឆ្នាំកន្លងមក[179] លោក មាស មុត បានរស់នៅដោយទទួលរងសម្ពាធ និង ការមាក់ងាយជាសាធារណៈ ដោយសារត្រូវបានដាក់ឱយស្ថិតក្រោមការស៊ើបអង្កេតលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មជាតិ ដោយគ្មានចម្លើយជាស្ថាពរថា តើគាត់នឹងប្រឈមនឹងការជំនុំជម្រះឬយ៉ាងណាឡើយ។ គាត់ត្រូវបានចោទប្រកាន់ដោយ ស.ច.ស.អ. ម្នាក់ ប៉ុន្តែ ដឹងមុនថា គ្មានឱកាសជំទាស់តវ៉ានឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះឡើយ - ថាតើត្រូវជំនុំជម្រះដោយ អ.វ.ត.ក. ឬ ក្នុងតុលាការកម្ពុជា ឬយ៉ាងណានោះទេ - ដែលបច្ចុប្បន្នតាមលងបន្លាចគាត់ និង គ្រួសាររបស់គាត់ជារៀងរហូត។

---

[174] ដីកាដំណោះស្រាយ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ឯកសារ D267។

[175] សេចក្តីពិចារណារបស់ អ.ប.ជ. អន្តរជាតិលើញត្តិសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ ៣៧។

[176] *ផ្ទុយពី* សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ៣៥១-៥៨។ លោក មាស មុត ត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរទៅប្រទេសថៃ ដើម្បីទទួលបានការថែទាំវេជ្ជសាស្ត្រ ទៅតាមការយល់ព្រម នៅពេលត្រូវបានចោទប្រកាន់ដោយ ស.ច.ស.អ. Bohlander។

[177] *ផ្ទុយពី* សេចក្តីពិចារណារបស់ អ.ប.ជ. អន្តរជាតិលើញត្តិសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ ៤៥។

[178] *ដូចខាងលើ* កថាខណ្ឌ ៣៥ ដែលសម្រេចថា ស្ថានភាពសុខភាព និងវ័យរបស់ជនត្រូវចោទ ជាកត្តាដែលត្រូវពិចារណាក្នុងការវាយតម្លៃលើការពន្យារពេល។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយនៃការបង្ហាញខ្លួនលើកដំបូងរបស់លោក មាស មុត ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ D174។

[179] សេចក្តីពិចារណារបស់ អ.ប.ជ. អន្តរជាតិលើញត្តិសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ ៣៥។

៥៥. វានឹងអស់រយៈពេល ៤៣ ឆ្នាំ ក្រោយព្រឹត្តិការណ៍ក្នុងរឿងក្តី ០០៣ មុនពេលលោក មាស មុត អាចរំពឹងថាត្រូវបានជំនុំជម្រះដោយសមហេតុផល - ដោយសន្មតថា អ.ប.ជ. យល់ស្របដោយសំឡេងភាគច្រើនលើសលុប ដើម្បីបញ្ជូនគាត់ទៅជំនុំជម្រះ[180]។ យូរៗទៅ "ការចងចាំរបស់សាក្សីកាន់តែថយចុះ សាក្សីអាចស្លាប់ ឬ មិនអាចតាមដានរកប្រភពបាន ភស្តុតាងបាត់បង់បន្តិចម្តងៗ ឬ លែងមាន"[181]។ លទ្ធភាពនៃការជំនុំជម្រះក្តីដោយយុត្តិធម៌សម្រាប់លោក មាស មុត - កុំថាឡើយដល់ការជំរុញនាំទៅដល់ការស្វែងរកការពិត - កំពុងថយចុះយ៉ាងឆាប់រហ័ស។

### គ. ដំណើរការនីតិវិធីជំនុំជម្រះ និង បណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី ០០៣ នឹងស៊ីរយៈពេលយ៉ាងតិច បួន ឆ្នាំ ជាមួយនឹងលទ្ធផលដែលមិនអាចចៀសរួច

៥៦. នៅឆ្នាំ ២០២៦ លោក មាស មុត អាចរំពឹងថាទទួលបានសាលដីកាពី អ.ជ.ត.ក. ដែលតម្កល់ការសម្រេចឱយរួចការចោទប្រកាន់របស់ អ.ជ.ស.ដ. បន្ទាប់ពី អ.ជ.ស.ដ. បានខ្វែងយោបល់គ្នាលើអញ្ញត្រកម្មដោយសារកង្វះយុត្តាធិការ - *ប្រសិនបើ* អ.ប.ជ. ព្រមព្រៀងគ្នាដោយសំឡេងភាគច្រើនលើសលុប ដើម្បីបញ្ជូនលោក មាស មុត ទៅជំនុំជម្រះ និង *ប្រសិនបើ* គ្មានការពន្យារពេលដែលមិនអាចយល់ដឹងជាមុនទេនោះ។ ការបង្ខិលលោក មាស មុត ក្នុងការបែកខ្ញែកនៅ អ.វ.ត.ក. អស់រយៈពេល ១៨ ឆ្នាំ បំពានលើភាពឆាប់រហ័ស និង នាំឱយមានការរំលោភពន់ពេកណាស់លើសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។

៥៧. ជាក់ស្តែង ដោយសារតែក្របខណ្ឌពេលវេលាកន្លងមករបស់ អ.ជ.ស.ដ. ការជំនុំជម្រះទំនងនឹងមិនចាប់ផ្តើមនោះទេ រហូតដល់ខែឧសភា ឆ្នាំ ២០២២ បន្ទាប់ពីសវនាការលើការគ្រប់គ្រងការជំនុំជម្រះ និង លើបណ្តឹងអញ្ញត្រកម្ម[182]។ សម្រាប់បញ្ហាផ្នែកយុត្តាធិការកំណត់ អ.ជ.ស.ដ. ត្រូវសម្រេច

---

[180] យ៉ាងឆាប់បំផុតគឺនៅឆ្នាំ ២០២២ *សូមមើល ខាងក្រោម* កថាខណ្ឌ ៥៧។

[181] *សូមមើល ស្ថានភាពក្នុងប្រទេសមីយ៉ាន់ម៉ា* សំណុំរឿងលេខ ICC-RoC46(3)-01/18-37 សេចក្តីសម្រេចលើ "សំណើរបស់ព្រះរាជអាជ្ញាសុំឱ្យចេញសេចក្តីសម្រេចលើយុត្តាធិការអនុលោមតាមមាត្រា ១៩ (៣) នៃលក្ខន្តិកៈ" ចុះថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០១៨ កថាខណ្ឌ ៨៦។ *សូមមើលផងដែរ* សេចក្តីពិចារណារបស់ អ.ប.ជ. អន្តរជាតិលើញត្តិសុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ ៣៥ (ដែលសម្រេចថា អនុភាពនៃការពន្យារពេលដល់ភស្តុតាង និងសាក្សី ជាកត្តាដែលត្រូវពិចារណាក្នុងការវាយតម្លៃលើការពន្យារពេល)។

[182] *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០១៤ ឯកសារ E313 ("សាលក្រមសំណុំរឿង ០០២/១") កថាខណ្ឌ ៣-៧។ អង្គជំនុំជម្រះ

ដោយសំឡេងភាគច្រើនលើសលុបថា តើ លោក មាស មុត ស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ឬទេ[183]។ ដោយ សារតែវិធាន ៨៩(១) កំណត់ថា "ដំណើរការនីតិវិធីត្រូវបន្ត *រៀរលែងតែ* [អ.ជ.ស.ដ. ] *ចេញសេចក្ដីសម្រេចភ្លាមៗ* ដែលមានអនុភាពបញ្ចប់ដំណើរការនីតិវិធី" ហើយ សវនាការលើអង្គសេចក្ដីនឹងបន្ត រៀរលែងតែ អ.ជ.ស.ដ. សម្រេចដោយសំឡេងភាគច្រើនលើស លុបក្នុងការបញ្ចប់រឿងក្ដីនេះ។

៥៨. សន្មតថា អ.ជ.ស.ដ. មិនបញ្ចប់រឿងក្ដីដោយសារកង្វះយុត្តាធិការបុគ្គល នោះការជំនុំជម្រះទំនង អាចស៊ីពេលយូរដូចក្នុងរឿងក្ដី ០០១ និង រឿងក្ដី ០០២/១ (មួយទៅពីរឆ្នាំ) ដោយរំពឹងថា សាល ក្រមអាចត្រូវបានចេញរយៈពេលប្រាំបួនខែក្រោយមក[184]។ តាមវិធាន ៩៨(៤) ដែលឆ្លុះបញ្ចាំងពី មាត្រា ៤(ក) នៃកិច្ចព្រមព្រៀង តម្រូវឱយមានសំឡេងភាគច្រើនលើសលុប ទើបអាចផ្ដន្ទាទោស។

៥៩. សន្មតថា លោក មាស មុត ត្រូវបានសម្រេចឱយរួចពីការចោទប្រកាន់ - ជាការសន្មតសមហេតុ ផលដោយពិចារណាលើសេចក្ដីថ្លែងការណ៍របស់ចៅក្រមជាតិនៃ អ.ជ.ស.ដ. ក្នុងរឿងក្ដី ០០៤/២ ដែលថា រឿងក្ដីនេះត្រូវបានច្រានចោលដោយផ្អែកតាមសេចក្ដីពិចារណារបស់ អ.ប.ជ.[185] - ហើយ ស.ព.អ. ប្ដឹងឧទ្ធរណ៍ជំទាស់ការសម្រេចឱយរួចពីការចោទប្រកាន់នោះ អញ្ចឹង សាលដីកាបស់ អ.ជ.ត.ក. អាចរំពឹងថាចេញនៅឆ្នាំ ២០២៦[186]។ វិធាន ១១១ ដែលឆ្លុះបញ្ចាំងពីសំឡេងភាគច្រើន លើសលុបសម្រាប់ អ.ជ.ត.ក. ក្នុងមាត្រា ៤(ខ) នៃកិច្ចព្រមព្រៀង កំណត់ថា "កាលណា" បណ្ដឹង សាទុក្ខត្រូវបានបដិសេធ នោះសាលក្រមរបស់ អ.ជ.ស.ដ. ត្រូវចូលជាស្ថាពរ និង មិនអាចតវ៉ាបាន

---

សាលាដំបូងក្នុងរឿងក្ដី ០០២ បានចំណាយពេលដប់មួយខែ សម្រាប់ការទទួលពិនិត្យរឿងក្ដីរបស់អង្គជំនុំជម្រះសាលាដំបូង នៅ ថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១១ និង សវនាការបឋម។

[183] មាត្រា ៤ (ក) នៃកិច្ចព្រមព្រៀង។

[184] *រឿងក្ដី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ សាលក្រម ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ E188 កថាខណ្ឌ ១០។ សាលក្រមសំណុំរឿង ០០២/១ កថាខណ្ឌ ៨។

[185] សេចក្ដីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី ០០៤/២ ទំព័រ ៣ ដែលថា សំណុំរឿង ០០៤/២ ត្រូវបានបិទ បញ្ចប់ដោយការសម្រេចរបស់ អ.ប.ជ. និងថា "នឹងពុំមានការជំនុំជម្រះក្ដី អោ អាន នៅពេលនេះ ឬនៅពេលអនាគតឡើយ"។

[186] ក្នុងរឿងក្ដី ០០១ សាលដីកាត្រូវបានចេញក្នុងរយៈពេល ១៨ ខែក្រោយការចេញសាលក្រម។ *រឿងក្ដី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28។ ក្នុង រឿងក្ដី ០០២/១ សាលដីកាត្រូវបានចេញក្នុងរយៈពេល ២៧,៥ ខែ ក្រោយការចេញសាលក្រម។ *រឿងក្ដី នួន ជា និងអ្នកផ្សេង ទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36។

ទៀតឡើយ"។ មានន័យថា ការសម្រេចឱយរួចផុតពីបទចោទប្រកាន់ដោយ អ.ជ.ស.ជ. មានអនុភាព។

### ឃ. អ.ប.ជ. ត្រូវតែបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ វៀរលែងតែ អ.ប.ជ. បង្វែរ និង សម្រេចដោយសំឡេងភាគច្រើនលើសលុប ដើម្បីបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ

៦០. ប្រសិនបើ អ.ប.ជ. មិនអាចស្រុះស្រួលគ្នាលើមតិទូទៅ ឬ ឥតមានសំឡេងភាគច្រើនលើសលុប និង មិនអាចចេញសេចក្តីសម្រេចដែលស្អាតពរ និង ដែលចងកាតព្វកិច្ច ក្នុងការបញ្ចប់ដំណើរការនីតិវិធីមុនជំនុំជម្រះនៃរឿងក្តី ០០៣ ដោយបំពេញកាតព្វកិច្ចដ៏សំខាន់របស់ខ្លួន ដើម្បីធានាសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ទេ នោះ អ.ប.ជ. ត្រូវបញ្ចប់ដំណើរការនីតិវិធីក្នុងរឿងក្តី ០០៣ នេះ បោះត្រា និង ដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារ ដើម្បីជៀសពីការរំលោភលើនីតិវិធី និង ការថ្លោះធ្លោយលើភាពអយុត្តិធម៌។

៦១. អ.ប.ជ. "ទទួលខុសត្រូវក្នុងការធានា នៅក្នុងដំណាក់កាលស៊ើបសួរ ថា គោលការណ៍គ្រឹះ ដែលជាមូលដ្ឋាននៃនីតិវិធីព្រហ្មទណ្ឌជាធរមាននៅចំពោះមុខ អ.វ.ត.ក. ត្រូវបានគោរព"[187]។ ការទទួលខុសត្រូវដែលមិនធ្វើតាមឥស្សរចិត្ត ត្រូវការឱយ អ.ជ.ប. ធានាថា ដំណើរការនីតិវិធីត្រូវបានធ្វើឡើង ទៅតាមបទដ្ឋានអន្តរជាតិស្តីពីដំណើរការត្រឹមត្រូវ[188] រួមទាំងការបញ្ចប់រឿងក្តី ដោយសារតែការរំលោភនីតិវិធី - ដែលជាទ្រឹស្តីត្រូវបានទទួលស្គាល់ជាអន្តរជាតិ មានចែងនៅក្នុងកិច្ចព្រមព្រៀងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មានចែងក្នុងច្បាប់កម្ពុជា និង ត្រូវបានទទួលស្គាល់ក្នុងយុត្តិសាស្ត្ររបស់ អ.វ.ត.ក.[189]។

---

[187] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៥២។

[188] *សូមមើល ដូចខាងលើ*។ *សូមមើលផងដែរ* មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ មាត្រា ១២ (២) នៃកិច្ចព្រមព្រៀង។ មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[189] *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៤២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំឲ្យកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ១០។ ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៧ ឯកសារ D249/6 កថាខណ្ឌ ១៦។

៦២. កិច្ចព្រមព្រៀង ចែងយ៉ាងច្បាស់ពីការបញ្ចប់រឿងក្តី តាមរយៈការផ្អាកនីតិវិធីជាអចិន្ត្រៃយ៍ ដោយប្រមើលមើលយ៉ាងច្បាស់ពីការដកខ្លួនរបស់ អ.ស.ប. ចេញពីកិច្ចព្រមព្រៀង និង បញ្ឈប់ជំនួយឧបត្ថម្ភរបស់ អ.ស.ប. ដល់ អ.វ.ត.ក. ក្នុងកាលៈទេសៈមួយចំនួន ដូចជា នៅពេលដែល អ.វ.ត.ក បញ្ឈប់ដំណើរការតាមវិធីដែលអនុលោមតាមខ្លឹមសារនៃកិច្ចព្រមព្រៀង[190]។ ទោះបីជា អ.ស.ប. មិនបានដកខ្លួនចេញពីកិច្ចព្រមព្រៀងក្តី ក៏ អ.វ.ត.ក. បានបញ្ឈប់ដំណើរការក្នុងរឿងក្តី ០០៣ តាមវិធីដែលអនុលោមតាមខ្លឹមសារនៃកិច្ចព្រមព្រៀង ៖ ពុំមានលទ្ធភាពសមហេតុផល ដែលលោក មាស មុត ត្រូវបានជំនុំជម្រះក្នុងរយៈពេលសមស្រប[191] ឬក៏ពុំមានលទ្ធភាពសមហេតុផលថា នៅទីបំផុត លោក មាស មុត នឹងត្រូវបានកាត់ឱយជាប់ទោសដែរ[192]។

៦៣. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ចែងថា កាលបើនីតិវិធីកម្ពុជាពុំបានរែកញែកពីករណីពិសេសណាមួយទេ នោះគេអាចស្វែងរកការណែនាំពីកម្រិតអន្តរជាតិបាន[193]។ អនុលោមតាមទ្រឹស្តីដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិស្តីពីការរំលោភនីតិវិធី នោះ អ.ប.ជ. អាច "បដិសេធមិនអនុវត្តតាមយុត្តាធិការរបស់តុលាការ ក្នុងករណីថាការអនុវត្តឆន្ទានុសិទ្ធិនេះ អាចធ្វើឱយមានការបំពាន*ធ្ងន់ធ្ងរ* និង*ជាក់ស្តែង* ទៅលើសិទ្ធិជនជាប់ចោទ ដែលនឹងនាំឱយអន្តរាយដល់សុចរិតភាពរបស់តុលាការ"[194]។ ទោះជាផ្អែកតាមឆន្ទានុសិទ្ធិ ដោយពិចារណាពីកាលៈទេសៈច្បាស់លាស់ អ.ប.ជ. មិនអាច "យល់ឃើញ [ថា] មានការរំលោភនីតិវិធីហើយ បែរជាបដិសេធមិនអនុវត្តយុត្តាធិការ

---

[190] មាត្រា ២៨ នៃកិច្ចព្រមព្រៀង។

[191] *សូមមើល ខាងលើ* កថាខណ្ឌ ៥១-៥៥។

[192] *សូមមើល ខាងលើ* កថាខណ្ឌ ៥៦-៥៩។

[193] មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ ក្រៅពីនេះ "មាត្រា ១៤ នៃកតិកាសញ្ញា ICCPR ចែងពីសិទ្ធិដ៏សំខាន់*ដែលនឹងគ្របដណ្តប់លើនីតិវិធីក្នុងស្រុក...*"។ *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៤២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី ខែសីហា ឆ្នាំ ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ១៣ (ការគូសបញ្ជាក់បន្ថែម)។

[194] *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៤២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ២២-២៣។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង El Sayed* សំណុំរឿងលេខ CH/AC/2010/02 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ចៅក្រមអង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងយុត្តាធិការ និងគោលជំហរ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ កថាខណ្ឌ ៤៦។

របស់ខ្លួន ដោយការផ្អាកជាអចិន្ត្រៃយ៍ ដូចនេះ គឺការបញ្ចប់ដំណើរការនីតិវិធី ដោយមិនបាច់មានការវិនិច្ឆ័យទោសនោះឡើយ "[195]។

៦៤. ស.ច.ស. និង អ.ជ.ត.ក. បានយល់ឃើញថា នីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងពីការបញ្ចប់ដំណើរការនីតិវិធី។ ផ្អែកលើ "ការសិក្សាយ៉ាងច្រើនអំពីច្បាប់ទាក់ទងនឹងការផ្អាកនីតិវិធី ទាំងច្បាប់ជាតិ ទាំងច្បាប់អន្តរជាតិ" ស.ច.ស. "ជឿជាក់ថា ទាំងច្បាប់កម្ពុជា ទាំងច្បាប់អន្តរជាតិមានចែងអំពីគន្លឹះគម្រូ (សេណារីអូ) ដែលការចេញដីកាបែបនេះគឺសមស្រប"[196]។ តាមរយៈការថ្លែងថា បណ្តឹងអាជ្ញាអាចមិន "រលត់" លើកលែងតែក្នុងស្ថានភាពដែលពាក់ព័ន្ធនឹងមរណភាពនៃជនជាប់ចោទ ការផុតអាជ្ញាយុកាល ការលើកលែងទោស និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និង*អាជ្ញាអស់ជំនុំ (res judicata)* អ.ជ.ត.ក. បានពន្យល់ថា ច្បាប់កម្ពុជា "ចែងពីអំណាចក្នុងការ "បង្អង់" ឬ "ផ្អាក" ដំណើរការនីតិវិធីក្នុងកាលៈទេសៈជាក់លាក់មួយចំនួន*ដោយសារតែជាឧបសគ្គ* ចំពោះដំណើរការនីតិវិធី..."[197]។

៦៥. ការខ្វែងយោបល់គ្នាដែលលើកឡើងជាទូទៅថា សហព្រះរាជអាជ្ញា ស.ច.ស. និង អង្គជំនុំជម្រះ - ថាតើលោក មាស មុត គួរត្រូវបានបញ្ជូនទៅជំនុំជម្រះឬយ៉ាងណានោះ - បង្កការរាំងស្ទះតឹងតែងលើការអនុវត្តនីតិវិធី។ ក្រៅពីការស៊ើបអង្កេតរយៈពេល ១៣ ឆ្នាំ ដោយគ្មានសេចក្តីសម្រេចបញ្ចប់ ក្រៅពីភាពជាប់គាំងដែលបណ្តាលមកពីការខ្វែងយោបល់គ្នាយ៉ាងតឹងតែង ក្រៅពីការពន្យារពេលបន្ថែមទៀត និង ភាពជាប់គាំងដោយសារភាពស្មាក់ស្មើរ ការជួសជុលកំហុស និង ការចោទប្រកាន់ទៅវិញទៅមក ដែលអាចរំពឹង (ដូចទិវាផ្លាស់វេនរាត្រី) លោក មាស មុត ជាប់ផុងក្នុងកាលៈទេសៈវិលទៅវិលមកម្តងហើយម្តងទៀត ដែល អ.ប.ជ. បានដឹងយ៉ាងជាក់ច្បាស់ថា នឹងនាំទៅរកលទ្ធ

---

[195] *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៤២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ២២។

[196] សេចក្តីសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៧ ឯកសារ D249/6 កថាខណ្ឌ ១៦។

[197] *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (១៦) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធិ ដោយឥតលក្ខខណ្ឌ ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១២ ឯកសារ E138/1/10/1/5/7 កថាខណ្ឌ ៣៨ (ការគូសបញ្ជាក់បន្ថែម)។

ផលដូច្នេះ ព្រោះឆាកល្ខោននេះបានលេចឡើងរួចទៅហើយនៅ អ.វ.ត.ក. ក្នុងរយៈពេលប្រាំបីខែ - នៅចន្លោះការដាក់បញ្ចូលសេចក្តីពិចារណារឿងក្តី ០០៤/២ និងរឿងក្តី ០០៣ ទៅក្នុងបណ្ណសារ[198]។

៦៦. អ.ប.ជ. បានសន្និដ្ឋានជាឯកច្ឆ័ន្ទថា ស.ច.ស. បានរំលោភនីតិវិធីជាប្រព័ន្ធ ៖

ក. ស.ច.ស. "បានប្រព្រឹត្តកំហុសអង្គច្បាប់ដ៏ធំធេង នៅក្នុងករណីនេះ ដោយយល់ឃើញថាក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក. អនុញ្ញាតឱយចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា"[199] ដែល"ធ្វើឱយអន្តរាយដល់មូលដ្ឋាននៃប្រព័ន្ធចម្រុះ និង ដំណើរការដោយត្រឹមត្រូវរបស់ អ.វ.ត.ក."[200]។

ខ. ស.ច.ស. "បានដឹងពីការលំបាកដែលបណ្តាលមកពីសកម្មភាពរបស់ពួកគាត់ មិនត្រឹមតែទៅលើបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះទេ តែហួសពីដំណាក់កាលបណ្តឹងឧទ្ធរណ៍មុនជំនុំជម្រះនៃដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ទៅទៀត"[201] ប៉ុន្តែ បានគេចវេសដោយគ្មានប្រណីពីការអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការរបស់ពួកគាត់ ក្នុងការសម្រេចលើបញ្ហា ដែលពួកគាត់បានទទួលបណ្តឹងឱយពិនិត្យ[202]។

គ. ស.ច.ស. "ប្រហែលបានប៉ុនប៉ងធ្វើឱយបរាជ័យដល់គោលជំហរដើម ហើយរំខានដល់សិទ្ធិអំណាចរបស់ [អ.ប.ជ.]" តាមរយៈការព្រមព្រៀងគ្នាក្នុងការចេញដីកាដំណោះស្រាយដាច់ពីគ្នា និង ផ្ទុយគ្នាក្នុងពេលតែមួយ[203]។ និង

---

[198] រឿងក្តី ០០៤/២ ត្រូវបានបោះត្រា និង ដាក់បញ្ចូលទៅក្នុងបណ្ណសារ នៅថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០២០ ហើយសេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ ត្រូវបានចេញនៅថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០២១។ *សូមមើល រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស ដីកាបង្គាប់ឲ្យបោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០២០ ឯកសារ D363/3។

[199] សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៣ កថាខណ្ឌ ៨៨។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១០៥ ដែល អ.ប.ជ. អះអាងថា សហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្ត "កំហុសអង្គច្បាប់យ៉ាងច្បាស់ក្រឡែតដែលសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតបានពឹងផ្អែកទៅលើនោះ"។

[200] *ដូចខាងលើ* កថាខណ្ឌ ១០៦។

[201] *ដូចខាងលើ* កថាខណ្ឌ ១០៧។

[202] *ដូចខាងលើ* កថាខណ្ឌ ១០៥។

[203] *ដូចខាងលើ* កថាខណ្ឌ ១០៨។

ឃ. "កំហុសឆ្គងរបស់ ស.ច.ស. បានធ្វើឱយខូចខាតដល់ប្រព័ន្ធទាំងមូល ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ" និង "*ការអនុវត្តដោយខុសឆ្គង* របស់ ស.ច.ស. អាចមានតម្លៃស្មើនឹងការបដិសេធភាពអយុត្តិធម៌"[204]។

៦៧. ទោះបីសេចក្តីសម្រេចទាំងនេះគ្មានគុណតម្លៃ (ដែលលើកឡើងដោយមេធាវីការពារក្តី)[205] ដូចវាមិនពាក់ព័ន្ធដែរ សម្រាប់ឱយ អ.ប.ជ. បច្ចុប្បន្ន ពន្យារពេលបន្ថែមទៀត ដោយខកខានមិនចាត់វាល់វិធានការចាំបាច់ទាំងអស់ ក្នុងល្បឿនឥតរួញរាដើម្បីបញ្ចប់ដំណើរការនីតិវិធីប្រឆាំងនឹងលោក មាស មុត ជាចំនួនមិនតិចជាងការរំលោភនីតិវិធី។ និយាយដោយឡែក ប្រសិនបើ អ.ប.ជ. បញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ ដោយដឹងដែរថា សិទ្ធរបស់ លោក មាស មុត ក្នុងការទទួលបានដំណើរការនីតិវិធីឆាប់រហ័ស នឹងត្រូវរងការប៉ះពាល់ដោយសារ តែការយល់ឃើញខុសគ្នាដែលមិនអាចផ្សះផ្សាបាន និង ភាពចចេសដែលស្រដៀងគ្នានឹងអ្វីដែលបានកើតឡើងរវាងចៅក្រមជាតិ និង ចៅក្រមអន្តរជាតិនៃ អ.ប.ជ. នោះ អ.ប.ជ. - ដោយមានការដឹងឮ និង ការទទួលខុសត្រូវពេញលេញ - ក៏គួរចូលរួមពាក់ព័ន្ធក្នុងប្រភេទនៃការរំលោភនីតិវិធីដូចអ្វីដែលខ្លួនបានអះអាងថា ស.ច.ស. បានប្រព្រឹត្តដែរ។

៦៨. មានតែ អ.ប.ជ. ប៉ុណ្ណោះដែលទទួលប្តឹងពិនិត្យ និង មានសិទ្ធិអំណាចតាមផ្លូវតុលាការ ក្នុងការបោះត្រា និង ដាក់បញ្ចូលរឿងក្តី ០០៣ ទៅក្នុងបណ្ណសារ។ បន្ទាប់ពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងនេះ សំណុំរឿងនេះត្រូវបានបញ្ជូនទៅ អ.ប.ជ. អនុលោមតាមវិធាន ៦៩(១)។ ទោះជាវិធាន ៦៩(២)(ខ) - ជាវិធានតែមួយគត់ក្នុងក្របខណ្ឌ អ.វ.ត.ក. ពាក់ព័ន្ធនឹងការបោះត្រា និង ការដាក់បញ្ចូលរឿងក្តីទៅក្នុងបណ្ណសារ - ចែងថា ស.ច.ស. ទទួលខុសត្រូវលើការបោះត្រា និង

---

[204] *ដូចខាងលើ* កថាខណ្ឌ ១០៨។

[205] សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺ កថាខណ្ឌ ១៥-៣៩។ សារណាបន្ថែមរបស់ មាស មុត កថាខណ្ឌ ២៧-៤៣។ សំណើរបស់ មាស មុត សុំធ្វើអន្តរាគមន៍ កថាខណ្ឌ ១១។ ចម្លើយរបស់ មាស មុត តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសហចៅក្រមស៊ើបអង្កេតសុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០២១ ឯកសារ D270/4 កថាខណ្ឌ ១៥។ *សូមមើលផងដែរ* មាត្រា ៥(១), ៧(៤) នៃកិច្ចព្រមព្រៀង។ មាត្រា ២៧ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ វិធាន (១), ១៤(២), ១៤(៧), ៧២(១), ៧២(២), ៧៧(១៣)(ក), ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង។ *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស. (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ២៧៤ ដែលសម្រេចថា ស.ច.ស. "មិនមានកាតព្វកិច្ច" ក្នុងការជូនដំណឹង អ.ប.ជ. ទេ នៅពេលពួកគេមិនបានព្រមព្រៀងលើបញ្ហាណាមួយដែលនៅចំពោះមុខ។

ការដាក់បញ្ចូលរឿងក្ដីទៅក្នុងបណ្ណសារ ប្រសិនបើ *គ្មាន* បណ្ដឹងឧទ្ធរណ៍ វិធាន ៦៩ មិនត្រូវបាន មើលឃើញថា ត្រូវយកមកវែកញែកពីសេណារីអូនៃដីកាដំណោះស្រាយផ្ទុយគ្នានោះទេ (កុំថា ឡើយដល់ដីកាដំណោះស្រាយដែលចេញដោយខុសច្បាប់)។ ដោយសារតែសិទ្ធិអំណាចដែលជាប់ ជាមួយរបស់ អ.ប.ជ. ក្នុងនាមជាយុត្តាធិការចុងក្រោយលើការស៊ើបអង្កេត[206] តក្កវិជ្ជាតម្រូវថា អ.ប.ជ. មានសិទ្ធិអំណាចក្នុងការបញ្ចប់ បោះត្រា និង បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ។

៦៩. ការ"ពន្យារពេលហួសហេតុ និង ដែលអាចចៀសវាងបាន" ក្នុងរឿងក្ដី ០០៣ "ប្រាសចាកពីក្រប ខណ្ឌគតិយុត្តិនៅ អ.វ.ត.ក."[207]។ អ.ប.ជ. គួរសំអាងលើសិទ្ធិអំណាចដែលជាប់ជាមួយរបស់ខ្លួន ក្នុងការបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ "ដើម្បីផ្ដល់ប្រសិទ្ធភាព ដល់គោលការណ៍ទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ដែលមានកម្រិតខ្ពស់ជាងក្នុងការសម្រេច សេចក្ដីលើសំណុំរឿងឱយបានត្រឹមត្រូវ និង ដើម្បីការពារសិទ្ធិរបស់ មាស មុត ក្នុងការទទួលបាន នូវការសម្រេចជាស្ថាពរលើសំណុំរឿងប្រឆាំងនឹងគាត់ឱយបានឆាប់រហ័ស" ដូចអ្វីដែល ស.ច.ស. សច្ចាថាធ្វើ ប្រសិនបើគ្មាននរណាផ្សេងនៅ អ.វ.ត.ក. មានឆន្ទៈក្នុងការផ្ដុំសេចក្ដីក្លាហានដើម្បី សម្រេចលើបញ្ហានេះ[208]។

## IV. សេចក្ដីសន្និដ្ឋាន

៧០. លោក មាស មុត កំពុងត្រូវបានបដិសេធសិទ្ធិរបស់គាត់ ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយ យុត្តិធម៌ និង ទទួលបានការសម្រេចជាស្ថាពរ និងឆាប់រហ័ស នៅក្នុងរឿងក្ដីប្រឆាំងនឹងរូបគាត់។ គាត់ត្រូវបានដាក់ឱយស្ថិតក្រោមកិច្ចស៊ើបសួរ តាំងពីថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៨។ ដំណើរការនីតិ វិធីប្រឆាំងនឹងគាត់ ត្រូវនៅរង់ចាំសម្រេច ដោយបំបែកជាពីរផ្នែកក្នុងផ្លូវតុលាការរបស់ អ.ប.ជ. ដែលចចេសប្រកាន់គោលជំហរផ្ទុយគ្នា ដែលនាំឱយប៉ះពាល់ដល់បទដ្ឋានអន្តរជាតិដែល អ.វ.ត.ក. ត្រូវអនុវត្តតាមយ៉ាងខ្ជាប់ខ្ជួន។

៧១. ដូចបានកត់សម្គាល់កន្លងមក ការបន្សល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលគ្មានការដោះស្រាយ តាមលងបន្លាចលោក មាស មុត ដោយអថាវរភាព ប្រៀបដូច ដាវរបស់ Damocle ជារឿងរហូត

---

[206] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ៥១។

[207] *ដូចខាងលើ* កថាខណ្ឌ ១៤៩។

[208] សេចក្ដីសម្រេចរបស់ ស.ច.ស. ស្ដីពីការបញ្ជូនសំណុំរឿង ០០៣ កថាខណ្ឌ ៤២។

គឺជាការដកហូតដែលមិនអាចកែតម្រូវ និង ជាអចិន្ត្រៃយ៍ នូវសិទ្ធិ ដែលការពារដោយរដ្ឋធម្មនុញ្ញ ថាត្រូវទទួលបានសច្ចធារណ៍និរទោស សិទ្ធិការពារក្តីរបស់គាត់ សិទ្ធិឱ្យកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់បញ្ចប់ក្នុងរយៈពេលសមរម្យ សិទ្ធិទទួលបានកិច្ចការពារស្មើភាពនៅចំពោះមុខ អ.វ.ត.ក. និង សិទ្ធិទទួលបានដំណោះស្រាយថាវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់គាត់[209]។ ស្ថិតក្រោមការសន្មតទុកជាមុនជារឿងរហូតថាមានទោស លោក មាស មុត មិនអាចជំទាស់តវ៉ាទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ព្រោះគ្មានយន្តការនីតិវិធីណាដើម្បីលើកចោលនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយដែលចេញដោយ អ.វ.ត.ក. និង គ្មានឱកាសបង្ហាញពីភាពគ្មានទោសរបស់គាត់ឡើយ។ តាមការយល់ឃើញរបស់ ស.ច.ស. ការទុក "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចោលឱ្យតាមលងបន្លាចជនត្រូវចោទ ដោយសារតែការបញ្ឈប់ប្រតិបត្តិការរបស់ អ.វ.ត.ក." បែបនេះ គឺ "មិនសមស្របតាមលក្ខខណ្ឌតម្រូវជាមូលដ្ឋាននៃនីតិរដ្ឋឡើយ"[210]។

៧២. ចៅក្រមនៃ អ.ប.ជ. មានសិទ្ធិអំណាច តាមពិតជាភារកិច្ច ក្នុងការទប់ស្កាត់ការរំលោភបន្ថែមទៀតលើសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង ក្នុងការរក្សាការពារសុចរិតភាពនៃកេរដំណែលរបស់ អ.វ.ត.ក.។ អ.ប.ជ. មិនអាច និង មិនត្រូវទុករឿងក្តីចោលក្នុងសភាពជាប់គាំងតាមផ្លូវតុលាការ ដោយមិនព្រមទទួលខុសត្រូវបញ្ហារបស់ពួកគេនោះទេ។ ដូចមេធាវីការពារក្តីបានផ្តល់យោបល់ ហើយដូចដែល អ.ជ.ត.ក. បានក្រើនរម្លឹកថា អ.ប.ជ. គួរបានស៊ើបអង្កេតរឿងក្តីនេះដោយផ្ទាល់ និង គួរបានចេញដីកាដំណោះស្រាយ ដែលមានសុពលភាពដោយខ្លួនឯង[211]។ គួរឱ្យសោកស្តាយ ដោយការបដិសេធមិនរៀវចាកពីឥរិយាបថពីមុនរបស់ខ្លួនក្នុងការស៊ើបអង្កេត ប្រកបដោយភាពរភាពលើរឿងក្តីនេះ ឬ ការចេញដីកាដំណោះស្រាយមួយដែលកែប្រែ និង ដោយការចេញសេចក្តីពិចារណាផ្ទុយគ្នាដាច់ពីគ្នា ចៅក្រមជាតិ និង ចៅក្រមអន្តរ

---

[209] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០១៩ ឯកសារ D267/4 កថាខណ្ឌ ៩។ សារណារបស់ មាស មុត ស្តីពីស្ថានភាពថវិការបស់ អ.វ.ត.ក. និងផលប៉ះពាល់លើរឿងក្តី ០០៣ ចុះថ្ងៃទី ៥ ខែមិថុនា ឆ្នាំ ២០១៧ ឯកសារ D249/2 កថាខណ្ឌ ២៩។

[210] សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់លើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៨ ឯកសារ D249 កថាខណ្ឌ ៥៤។

[211] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦១។ សេចក្តីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៣០។ សារណាបន្ថែមរបស់ មាស មុត កថាខណ្ឌ ៣០។ សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺ កថាខណ្ឌ ២២-២៣។ ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី ០០៣ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ឯកសារ D266/18.2 ម៉ោង ១១:៥៨:៣៩-១២:០៤:១៤ ។

ជាតិនៃ អ.ប.ជ. កំពុងថ្កោលទោសលោក មាស មុត ឱយប្រឈមនឹងភាពអសច្ចភាព ដំណើរការនីតិវិធីវិលវល់ ស្ថានការណ៍លំបាក ដូចជនត្រូវចោទក្នុងរឿងក្តី ០០៤/២ ដែរ ប៉ុន្តែ ការអន្តរាគមន៍របស់ អ.ជ.ត.ក. (ចំពោះចៅក្រមអន្តរជាតិបានស្តីបន្ទោស) នឹងនៅតែស្ថិតក្នុងការជាប់គាំងផ្នែកច្បាប់ ប៉ុន្តែនៅអលទ្ធភាពនៃដំណើការត្រឹមត្រូវនៅឡើយ ដែលបន្តឱយមានការភ័យខ្លាចខាងផ្លូវចិត្ត និង ស្នាមប្រឡាក់នៅក្នុងសង្គម ដែលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅតាមលងបន្លាចគាត់នោះ។

៧៣. វាដល់ពេលហើយ ដែល អ.ប.ជ ត្រូវចាត់ការឱយដាច់ស្រេច។ ប្រសិនបើ ចៅក្រមនៃ អ.ប.ជ. មិនមានសមត្ថភាព ក្នុងការចេញសេចក្តីសម្រេចតាមសំឡេងភាគច្រើនលើសលុប ក្នុងការបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះទេ នោះ អ.ប.ជ. *ត្រូវតែ*ប្រកាន់ខ្ជាប់ទៅតាមសម្បថតាមផ្លូវតុលាការរបស់ខ្លួន និង គោរពតាមច្បាប់យ៉ាងស្មោះត្រង់ ដោយអនុវត្តសិទ្ធិអំណាចរបស់ខ្លួន ក្នុងការបញ្ចប់ដំណើរការនីតិវិធីនេះ បោះត្រាសំណុំរឿង រួចដាក់បញ្ចូលវាទៅក្នុងបណ្ណសារ។ អនុវត្តផ្សេងពីនេះ ស្មើនឹង អ.ប.ជ. បោះបង់ទំនួលខុសត្រូវរបស់ខ្លួនចោល បោះបង់ទំនួលខុសត្រូវរបស់ខ្លួនចោល គឺជាការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិរបស់ លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។

អាស្រ័យហេតុនេះ អ.ប.ជ. គួរត្រូវ៖

ក. **យល់ឃើញ**ថា សំណើនេះអាចទទួលយកបាន។

ខ. **បញ្ចប់** សំណុំរឿង ០០៣។

គ. **បោះត្រា** សំណុំរឿង ០០៣។ និង

ឃ. **ដាក់បញ្ចូល** សំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ។

សូមលោកចៅក្រមទទួលយកសេចក្តីគោរពអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៧** ខែ**មិថុនា** ឆ្នាំ **២០២១**

**សហមេធាវីការពារក្តីលោក មាស មុត**

អាង ឧត្តម — Michael G. KARNAVA